# ក

# មាតិកា

## I- ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៣-០១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០១១០/០៤១ ស្តីពី ការតែងតាំង ឯកឧត្តម ចំនួន ០៥ រូប ជាទីប្រឹក្សា និង ជាជំនួយការ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា ១៧០០

១៣-០១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០១១០/០៤២ ស្តីពី ការតែងតាំង ឯកឧត្តម ទឹម ផន ជាទីប្រឹក្សា សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១៧០១

១៨-០១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០១១០/០៥៧ ស្តីពី ការតែងតាំងជាទីប្រឹក្សា សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា សម្រាប់នីតិកាលទី ២ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ចំនួន ០២ រូប ១៧០២

១៨-០១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០១១០/០៥៨ ស្តីពី ការតែងតាំង ឯកឧត្តម សំ នេត្រា ជាទីប្រឹក្សា សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ១៧០៣

២៦-០១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០១១០/០៧៣ ស្តីពី ការតែងតាំង ឯកឧត្តម ម៉ី វឌ្ឍា ជាទីប្រឹក្សា សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១៧០៤

០៤-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១២២ ស្តីពី ការតែងតាំង ឯកឧត្តម លឹម ឃួរ ជាជំនួយការ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១៧០៥

០៩-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៤២ ស្តីពី ការប្រោសព្រះរាជទាន ចំពោះ សព លោក ឡាច ស្វតិ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ជាកិច្ចបច្ឆាមរណៈ ១៧០៦

១០-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៤៣ ស្តីពី ការតែងតាំង ឯកឧត្តម ចំនួន ០២ រូប ជាទីប្រឹក្សា សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១៧០៧

១២-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៤៤ ស្តីពី ការលុបឈ្មោះលោក ខាំ ឡើង ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ២ ដែលត្រូវទទួលការផ្តន្ទាទោសដាក់ពន្ធនាគារ ចេញពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ១៧០៨

១២-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៤៥ ស្តីពី ការតែងតាំង ចៅក្រមអន្តរជាតិ ចៅក្រមអន្តរជាតិបំរុង នៅអង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំនួន ០៣ រូប ១៧០៩

១២-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៤៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម.លោកជំទាវ.អស់លោក និង លោកស្រី ចំនួន ១៨ រូប ១៧១០

១២-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៤៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម.លោកជំទាវ.អស់លោក និង លោកស្រី ចំនួន ១៨ រូប ១៧១១

១៥-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៤៨ ស្តីពី ការប្រោសព្រះរាជទាននូវគ្រឿង ឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ អស់លោក ចំនួន ១២ រូប ១៧១២

១៥-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៤៩ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍តាម ឋានន្តរស័ក្តិ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចំនួន ០១ រូប ដោយរក្សាឱ្យនៅបន្តការងារក្នុងមុខតំណែងនយោបាយដដែល និង ដាក់ឱ្យចូលនិវត្តន៍តាម ឋានន្តរស័ក្តិ នូវមន្ត្រីរាជការ ចំនួន ១៨ រូប ស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ១៧១៣

១៥-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៥០ ស្តីពី ការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តមបណ្ឌិត **អួន ព័ន្ធមុនីរ័ត្ន** នូវគ្រឿងឥស្សរិយយស ជាតួបការ ១៧១៥

១៥-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៥១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម.អស់លោក និង លោកស្រី ចំនួន ២៣៤ រូប ១៧១៦

១៥-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៥២ ស្តីពី ការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម **សេខ សន្តា** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ១៧២១

១៥-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៥៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម.លោកជំទាវ និង អស់លោក ចំនួន ២៣ រូប ១៧២២

## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ

០៩-០២-២០១០ -អនុក្រឹត្យលេខ ២៤ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ១៧២៣

# គ


-អនុក្រឹត្យលេខ ២៥ អនក្រ.**បក** ***(មិនទាន់បានទទួល)***

២៤-០២-២០១០ -អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពី ការបង្កើតគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ១៧២៦

១២-០២-២០១០ -អនុក្រឹត្យលេខ ១៤១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៧៣១

១២-០២-២០១០ -អនុក្រឹត្យលេខ ១៤២ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៧៣៧

១២-០២-២០១០ -អនុក្រឹត្យលេខ ១៤៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៧៣៨

១២-០២-២០១០ -អនុក្រឹត្យលេខ ១៤៤ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៧៣៩

១២-០២-២០១០ -អនុក្រឹត្យលេខ ១៤៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៧៤១

១២-០២-២០១០ -អនុក្រឹត្យលេខ ១៤៦ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ១៧៤៣

១៥-០២-២០១០ -អនុក្រឹត្យលេខ ១៤៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៧៤៨

១៥-០២-២០១០ -អនុក្រឹត្យលេខ ១៤៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៧៥០

១៥-០២-២០១០ -អនុក្រឹត្យលេខ ១៤៩ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៧៥២

១៥-០២-២០១០ -អនុក្រឹត្យលេខ ១៥០ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់តាមសញ្ញាប័ត្រជូនមន្ត្រីរាជការ ១៧៥៣

១៥-០២-២០១០ -អនុក្រឹត្យលេខ ១៥១ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ១៧៥៤

១៦-០២-២០១០ -អនុក្រឹត្យលេខ ១៥២ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៧៥៨

១៦-០២-២០១០ -អនុក្រឹត្យលេខ ១៥៣ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៧៥៩

១៦-០២-២០១០ -អនុក្រឹត្យលេខ ១៥៤ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៧៦០

១៦-០២-២០១០ -អនុក្រឹត្យលេខ ១៥៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៧៦១


## ២_សេចក្តីសម្រេច


១៩-០២-២០១០ -សេចក្តីសម្រេចលេខ ០៨ សសរ ស្តីពី ការកែសម្រួល និង រៀបចំការចងសម្ព័ន្ធមេត្រីភាព រវាងអង្គភាពកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន-អង្គភាពស៊ីវិល ១៧៦២

២២-០២-២០១០ -សេចក្តីសម្រេចលេខ ពិសេស ស្តីពី ការកែសម្រួល និង រៀបចំការចងសម្ព័ន្ធមេត្រីភាព រវាងអង្គភាពកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន-អង្គភាពស៊ីវិល ១៧៦៤

២២-០២-២០១០ -សេចក្តីសម្រេចលេខ ០៩ សសរ ស្តីពី ការនិរាករណ៍កិច្ចសន្យាលក់-ទិញអគ្គិសនី រវាងអគ្គិសនីកម្ពុជា និង អាជ្ញាធរអប្សរា សំរាប់យកទៅចែកចាយ នៅតំបន់ ១ តំបន់ ២ និង នៅក្នុងបុរីទេសចរណ៍ និង វប្បធម៌ ខេត្តសៀមរាប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ និង កិច្ចព្រមព្រៀងផ្ទេរសិទ្ធិ និង កាតព្វកិច្ចនៃកិច្ចសន្យាលក់-ទិញអគ្គិសនីពីក្រុមហ៊ុនអគ្គិសនីកម្ពុជា រវាងអាជ្ញាធរអប្សរា និង ក្រុមហ៊ុន ស៊ូជីង អេឡិចត្រូនិក (Sou Ching Electronic Co.,Ltd) ដើម្បីធ្វើការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ ១ តំបន់ ២ និង នៅក្នុងបុរីទេសចរណ៍ និង វប្បធម៌ ខេត្តសៀមរាប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ១៧៧១

## III.ការងារបណ្តាក្រសួង

### ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១២-០១-២០១០ -ប្រកាសលេខ ០២៨ សហវ.ប្រក ស្តីពី ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និង ទិញ-លក់ទ្រព្យបញ្ចាំ និង អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ១៧៧៣

២១-០១-២០១០ -ប្រកាសលេខ ០៣១ សហវ.ប្រក ស្តីពី ការបង្កើតការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និង ទិញ-លក់ទ្រព្យបញ្ចាំ និង អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ១៧៨៣

២៥-០១-២០១០ -សេចក្តីជូនដំណឹងលេខ ០០១ សហវ.ឧហ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និង ទិញ-លក់ទ្រព្យបញ្ចាំ និង ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ១៧៨៦

### ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៣០-៤-២០០៩ -លិខិតបញ្ជាក់លេខ ១៨៤០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូទីអាយ (ខេមបូឌា)** ១៧៨៧

៣០-៤-២០០៩ -លិខិតបញ្ជាក់លេខ ១៨៤១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាយ & ធី អេនធើធេនមេន** ១៧៨៩

៣០-៤-២០០៩ -លិខិតបញ្ជាក់លេខ ១៨៤៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាយអឹម៉ិន ប្រាវឌើរ** ១៧៩១

៣០-៤-២០០៩ -លិខិតបញ្ជាក់លេខ ១៨៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជីង ឆ្វេង អ៊ី អ៊ិនធើណេសិនណល** ១៧៩៣

៣០-៤-២០០៩ -លិខិតបញ្ជាក់លេខ ១៨៤៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គីស សីទីស គ្រុប លីមីធីត** ១៧៩៥

| | | |
|---|---|---|
| ៣០-៤-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៥០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផូខ ហ្វូ អ៊ិនវេសមេន-ឌីវេឡុបមេន** | ១៧៩៧ |
| ៣០-៤-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៥១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ.តី.អាយ.ធី** | ១៧៩៩ |
| ៣០-៤-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៥៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គាលីហ្វ័រនីញ៉ា បេគខឺរី អិលធីឌី** | ១៨០១ |
| ៣០-៤-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៥៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ូខ ចាខ អ៊ិនវេសមេន ឌីវេឡុបមេន** | ១៨០៣ |
| ៣០-៤-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៥៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី &ឌី (ខេមបូឌា) លីមីធីត** | ១៨០៥ |
| ៣០-៤-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៥៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៉ីល វេខរ** | ១៨០៧ |
| ៣០-៤-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៦៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ.ហ្វីស ខូ អិលធីឌី** | ១៨០៩ |
| ៣០-៤-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៦៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីស៊ីធីឌី អ៊ីមផត &អិចផត ខបភើរេសិន** | ១៨១១ |
| ១៩-៥-២០០៩ | -លិខិតបញ្ជាក់លេខ ២០២៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី ស៊ា** | ១៨១៣ |
| ១៩-៥-២០០៩ | -លិខិតបញ្ជាក់លេខ ២០៣០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថេង គ្រុឌីខ** | ១៨១៥ |

# ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៤១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : តែងតាំង :

១- ឯកឧត្តម **ប្រាក់ សុខណ្ណ** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

២- ឯកឧត្តម **គង់ សុភា** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

៣- ឯកឧត្តម **ហុង ឆាយ** ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អគ្គនាយក** ។

៤- ឯកឧត្តម **តូ ប៉ូយ** ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អគ្គនាយក** ។

៥- ឯកឧត្តម **អ៊ឹម ឡាចីន** ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អគ្គនាយក** ។

មាត្រា២ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

៣.ល.១០០១.០៤១ **នរោត្តម សីហមុនី**

លេខ:១៤៦ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**យុន ជិនកេន**

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០១១០/០៤៧

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **ទីម ផន** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.១០០១.០៤៧

**នរោត្តម សីហមុនី**

លេខៈ ១៤៥ ច.ល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០*

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៥៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នា សម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា សម្រាប់នីតិកាលទី២ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដូចមានរាយនាមខាងក្រោម :

- ឯកឧត្តម **ពៅ ណារិន**
- ឯកឧត្តម **សិន ស៊ីថុន**

**មាត្រា២:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*ព្រ.ល. ១០០១.០៥៧*

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០*

លេខ: ១៤៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែ កុម្ភៈ ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ជិនហេង

# ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៥៩

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **សំ ធេត្រា** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*៣/ល. ១០០១. ០៥៩*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០*

លេខ: ១៤៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១០
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០១១០/០៧៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **ម៉ី វណ្ណា** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣.៧.២០០១.០៧៣

**លេខ:១៤៧ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០១០
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៧៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **លឹម ឃួរ** ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*៣រល. ១០០៧. ១៧៤*

**នរោត្តម សីហមុនី**

**លេខៈ ១៤១ ច.ល**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១០*

**... ចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការនៃរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៨៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

សពលោក **ឡាច សួគិ**

នូវ

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ជាតិច្ចបដ្ឋាមរណៈ**

៣/ល. ១០០៧.១៨៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០*

**លេខ: ១៧៨ ច.ល**
**[illegible] ចម្លងចេញ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១០
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៤៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

__មាត្រា១__ : ត្រូវបានតែងតាំង :

១- **ឯកឧត្តម ម៉ាន់ ពុទ្ធិពល** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

២- **ឯកឧត្តម ម៉ូច សុខម៉ា** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

__មាត្រា២__ : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

__មាត្រា៣__ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*៣រល.១០០២.១៤៥*

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១០*

លេខ:១៧៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៨៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានលុបឈ្មោះលោក **ខាំ ខឿន** ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ២ ដែលត្រូវទទួលការផ្តន្ទាទោសដាក់ពន្ធនាគារ ចេញពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣ល.១០០៧.១៨៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១០*

លេខ:១៣៣ ច.ល

បើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃួន ឌិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៤៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់ព្រះរាជក្រមលេខ នស / រកម / ០៨០១ /១២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតឱ្យមានអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១០

## ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងចៅក្រមអន្តរជាតិ ចៅក្រមអន្តរជាតិបម្រុង នៅអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា :

១-លោកស្រី **Catherine Marchi-Uhel** ជាចៅក្រមអន្តរជាតិពេញសិទ្ធិ នៃអង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

២-លោកស្រី **Katinka Lahuis** ជាចៅក្រមអន្តរជាតិបម្រុង នៃអង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

៣-លោកស្រី **Florence Mumba** ជាចៅក្រមអន្តរជាតិបម្រុង នៃអង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣.លៈ.១០០២.១៤៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១០*

លេខៈ១៣៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ.ថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible]ឌីនរេន

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៨៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១-លោក ឯម ស៊ីថា

ខ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេនា** ចំពោះ :

១-ឯកឧត្តម កែវ ពិសិដ្ឋ
២-លោក ខាន់ វឌ្ឍនៈ
៣-លោក អ៊ុក ចរ៉ា

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១-លោក ឡុង ស៊ីណា
២-លោក ឡឹក អមរិន្ទ
៣-លោក កែវ រិទ្ធី
៤-លោក អ៊ូ ចណ្ឌារិទ្ធ

ឃ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១-លោកជំទាវ កែវ សំបួរ
២-លោកជំទាវ គង់ ម៉ាន់ថន
៣-លោកជំទាវ ម៉ាន់ ណាឌី
៤-លោកជំទាវ ស៊ឹម សុផល

ង-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ចំពោះ :

១-ឯកឧត្តម អ៊ុំ ចណ្ឌា

ច-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ចំពោះ :

១-លោក គឹម បញ្ញា
២-លោកស្រី លឹម សុខជា
៣-លោក អោម ផល្លី
៤-លោកវរសេនីយ៍ទោ តាត ចន
៥- លោកអនុសេនីយ៍ឯក អ៊ិត សុភាព

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣/ល. ១០០៧. ១៨៩

លេខៈ ១៧៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែ កុម្ភៈ ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១-ឯកឧត្តម **គង់ និមុល** ២-លោក **ឡៅម ចេងហេង**

៣-លោកវរសេនីយ៍ឯក **សៅ សុធន** ៤-លោក **ពាត ចាន់នី**

៥-លោក **ហ៊ាន់ គឹមស្រ៊ុន**

ខ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១-ឯកឧត្តម **ពេជ្រ គៅ** ២-លោកជំទាវ **ស្មឿង ម៉ាន់នី**

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

១-ឯកឧត្តម **ច័ន្ទ ចណ្ណា** ២-ឯកឧត្តម **ឡាយ ឫទ្ធី**

៣- លោកស្រី **ហ៊ឹម សុចណ្ណើរី** ៤-លោក **ចាន់ សា**

៥-លោក **ឯម អិន់** ៦-លោកវរសេនីយ៍ឯក **ឈុន ចណ្ណារិទ្ធិ**

ឃ-គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** ចំពោះ :

១-ឯកឧត្តម **មោត សុធារិន** ២-លោកវរសេនីយ៍ឯក **ម៉ាន់ កុសល**

៣-លោកវរសេនីយ៍ទោ **ខ៊ែង ឈុន**

ង-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ចំនួន ០២រូប

១-ឯកឧត្តម **លីម ហាចនី** ២-លោកជំទាវ **ស៊ីម សុផល**

៣/៧. ១០០៤. ១៤៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១០*

លេខ: ១៥៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១០
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ស៊ិន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូនចំពោះ :

១-លោក **ឃឹម យោន**

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូនចំពោះ :

| | | | |
|---|---|---|---|
| ១ | លោកវរសេនីយ៍ត្រី | **កែវ ជា** | អត្តលេខ ១២៤៣៩ |
| ២ | លោកអនុសេនីយ៍ឯក | **ម៉ិច រី** | អត្តលេខ ១៦២៥៥ |
| ៣ | លោកអនុសេនីយ៍ឯក | **ជា ដារ៉ា** | អត្តលេខ ៣៤១១២ |
| ៤ | លោកអនុសេនីយ៍ឯក | **គ្រួយ សេងហុង** | អត្តលេខ ១៦២៥៤ |
| ៥ | លោកអនុសេនីយ៍ទោ | **ឆេង សម្បត្តិ** | អត្តលេខ ៣៤១១១ |
| ៦ | លោកអនុសេនីយ៍ទោ | **គង់ សុធន** | អត្តលេខ ៣៤២៥១ |
| ៧ | លោកអនុសេនីយ៍ទោ | **មួង សុណៃ** | អត្តលេខ ១៥៩៤៧ |
| ៨ | លោកអនុសេនីយ៍ទោ | **លាង សារិទ្ធ** | អត្តលេខ ០១៦៣៨២ |
| ៩ | លោកអនុសេនីយ៍ត្រី | **ឃឿន ឃឿត** | អត្តលេខ ៣០៨៦៣ |
| ១០ | លោកអនុសេនីយ៍ត្រី | **ខៀវ សុវណ្ណ** | អត្តលេខ ០៥៧៨៦៣ |

១១-លោក **ហុង លាង**

១២-លោក **អេង លី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០*

៣.៧. ១០០២.១៥០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខ:១៥៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ម៉ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៤៩

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

ត្រា ១ : ត្រូវបានដាក់ឱ្យចូលនិវត្តន៍តាមឋានន្តរស័ក្តិ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចំនួន ០១ រូប ដោយរក្សាឱ្យនៅបន្តការងារក្នុងមុខតំណែងនយោបាយដដែល ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១ | ឯកឧត្ដម **អន ស៊ុំ** | ឧត្ដមមន្ត្រីថ្នាក់លេខ ១ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០ |

ា ២ : ត្រូវបានដាក់ឱ្យចូលនិវត្តន៍តាមឋានន្តរស័ក្តិនូវមន្ត្រីរាជការចំនួន ១៨ រូប ស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១ | ឯកឧត្ដម **លី ស៊ូ** | ឧត្ដមមន្ត្រីថ្នាក់លេខ ១ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ |
| ២ | ឯកឧត្ដម **ឡៅ ជា** | ឧត្ដមមន្ត្រីថ្នាក់លេខ ១ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១០ |

UME DU CAMBODGE
DU PALAIS ROYAL

| | | | |
|---|---|---|---|
| ៣ | ឯកឧត្តម **មួង ម៉យ** | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១០ |
| ៤ | ឯកឧត្តម **សែន សំគី** | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០ |
| ៥ | ឯកឧត្តម **ណៅ ណៃ** | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១០ |
| ៦ | ឯកឧត្តម **ប្រាក់ សារុន** | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១០ |
| ៧ | ឯកឧត្តម **ឃឹម សិលា** | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១០ |
| ៨ | ឯកឧត្តម **សំគុល សុខន** | ឧត្តមមន្ត្រីថ្នាក់លេខ ៤ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១០ |
| ៩ | ឯកឧត្តម **តោគ សំអេន** | ឧត្តមមន្ត្រីថ្នាក់លេខ ៤ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១០ |
| ១០ | ឯកឧត្តម **ឆាលំ សាន្ត** | ឧត្តមមន្ត្រីថ្នាក់លេខ ៤ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១០ |
| ១១ | ឯកឧត្តម **ឡៅ ប៊ុនធី** | ឧត្តមមន្ត្រីថ្នាក់លេខ ៥ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១០ |
| ១២ | ឯកឧត្តម **ឆូច សារុន** | ឧត្តមមន្ត្រីថ្នាក់លេខ ៦ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១០ |
| ១៣ | ឯកឧត្តម **ម៉ាន់ ឈឿន** | ឧត្តមមន្ត្រីថ្នាក់លេខ ៦ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១០ |
| ១៤ | ឯកឧត្តម **សុខ លក្ខិណា** | ឧត្តមមន្ត្រីថ្នាក់លេខ ៦ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១០ |
| ១៥ | ឯកឧត្តម **ពេជ គីមអេង** | ឧត្តមមន្ត្រីថ្នាក់លេខ ៦ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១០ |
| ១៦ | ឯកឧត្តម **ឃាត់ ទ៉ាត** | ឧត្តមមន្ត្រីថ្នាក់លេខ ៦ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១០ |
| ១៧ | ឯកឧត្តម **ជិន លី** | ឧត្តមមន្ត្រីថ្នាក់លេខ ៦ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១០ |
| ១៨ | ឯកឧត្តម **ជៀប ពិរ៍** | ឧត្តមមន្ត្រីថ្នាក់លេខ ៦ | ចូលនិវត្តន៍ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១០ |

ា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

ា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

ា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល. ១០០៤. ១៥១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០*

**លេខ: ១៤៧ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តមបណ្ឌិត អ៊ូន ព័ន្ធមុនីរ័ត្ន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.លេ. ១០០២. ១៥២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០

លេខ:១៣៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ កុម្ភៈ ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- ឯកឧត្តម សុខ ចិន្តា
២- ឯកឧត្តម ទី យ៉ាច
៣- ឯកឧត្តម ធីត គ្រឿនធុត្តា
៤- ឯកឧត្តម ហង់ ជួនណារ៉ុន
៥- ឯកឧត្តម យៀង យ៉ាណារ៉ា
៦- ឯកឧត្តម ជួ ចិវិត្ត
៧- ឯកឧត្តម ចឡឺ ចិស្សុត
៨- ឯកឧត្តម ហ៊ាន សាហ៊ីប

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

១- ឯកឧត្តម ស៊ឹម អៀង
២- ឯកឧត្តមឧត្តមសេនីយ៍ទោ រស់ សោម
៣- ឯកឧត្តមឧត្តមសេនីយ៍ទោ សុន គឹមសិន
៤- ឯកឧត្តម ប្រាក់ មិន
៥- ឯកឧត្តម គីម សុភ:
៦- ឯកឧត្តម ចាន់ សុធី
៧- ឯកឧត្តម ឈន សុភាព
៨- ឯកឧត្តម ចង់ សណ្តាប់
៩- ឯកឧត្តម ជាប ដាទុធ
១០- ឯកឧត្តម ឡាយ ព្រហស្ត
១១- ឯកឧត្តម សុខ សារាវុឌ្ឍ
១២- ឯកឧត្តម ម៉ី ម៉ាន់
១៣- ឯកឧត្តម អៀង សុនលី
១៤- ឯកឧត្តម នេត មុន្នី
១៥- ឯកឧត្តម ជា ធុធណា
១៦- លោក គីម ស្រេង
១៧- លោក សុខ សុផល

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១- ឯកឧត្តម ម៉ិញ បានគុសល
២- ឯកឧត្តម តើត រិទ្ធ
៣- ឯកឧត្តម ឈឹម សារ៉ែត
៤- ឯកឧត្តម ចឡុ ប៊ុនឥន្ទ្រាទុធ

៥- ឯមឧត្តម គាន ច័ន្ទមេត្តា
៦- ឯកឧត្តម ស៊ូ សុជាតិ
៧- ឯកឧត្តម ជា ឫទ្ធី
៨- លោក អ៊ុំ សីហា
៩- លោក ចាន់ ស៊ុំ
១០- លោក យស់ ស៊ីម៉ារ៉ាត់
១១- លោក កែប សាឫធ
១២- លោក ហ៊ឹង ពៅ
១៣- លោក នួន វិឡ្យ៉ា
១៤- លោក អ៊ឹម សិទ្ធីរ៉ា
១៥- លោក ហួង សុហួរ
១៦- លោក យ៉េត ជីណែល
១៧- លោក នួប សុធនវិចិត្រ
១៨- លោក ឈួម បណ្ណថារ៉ូ
១៩- ឯកឧត្តម វិត ឫទ្ធី
២០- លោក ចឡ្យ រ៉ូដាឫឡ
២១- ឯកឧត្តម ហាប រតនៈ
២២- ឯកឧត្តម រស់ សីលប៉ា
២៣- លោក ថៅ សុខមុនី
២៤- លោក នួច សុខសម្បត្តិ
២៥- លោក វ័ន្ត សំ
២៦- លោក ឌី ឡាំថា
២៧- លោក ឃួន ហ្សូលីន
២៨- លោក យូ គិរម្យ
២៩- លោក គួយ សាឫធ
៣០- លោក កែប បេចឡ្លន៍
៣១- លោក ប៊ូ ចឡ្យសុខា
៣២- លោក អួន ប៊ុនហាត់
៣៣- ឯកឧត្តម ងត វីរៈជេដ្ឋ
៣៤- លោក សែន សាយ
៣៥- លោក ប៉ែន ឫត្ថា
៣៦- លោក ស៊ឹម សំណាង
៣៧- លោក ប៊ូ ច័ន្ទគីរ៉ូ
៣៨- លោក ហ៊ួយ សុខ
៣៩- លោក លុន ម៉ារ៉ែត
៤០- លោក ច៉ាន់ គិរម្យ
៤១- ឯកឧត្តម ម៉ែន សេស
៤២- លោក ប៊ុន ប៊ុណ្ណារិទ្ធិ
៤៣- លោក ហ៊ាប សុផល
៤៤- លោក ស៊ាន ម៉ាឡូត
៤៥- លោក ហ៊ា នៅ
៤៦- លោកស្រី ស៊ុច គីមស៊ាន
៤៧- លោក ស្រី ឫធ
៤៨- លោក មាស ចាន់ដេត
៤៩- លោក ឆាយ រតនៈ

ឃ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ :

១- លោក គង់ សោភ័ណ្ឌ
២- លោក ឆា លាងហ៊ត
៣- លោក ឃ្លាំង បណ្ណផល
៤- លោក អ៊ុន ម៉ាឡ៊ីរ៉ី
៥- លោកជំទាវ ហេង សុគន្ធ
៦- លោក គៀង សត្ថាឫធ
៧- លោក ជូ ម៉ាន់នី
៨- ឯកឧត្តម ញឹម ខេមរា
៩- លោក សេង គង់
១០- លោក សេង សុចិន្តា

| | | | |
|---|---|---|---|
| ១១- លោក | ខឹម សិទ្ធិសែន | ១២- លោក | ម៉ុន ប៊ុនធឿន |
| ១៣- លោក | ម៉ាន់ ពុទ្ធិពល | ១៤- លោក | ឃុត សាខន |
| ១៥- ឯកឧត្តម | សេង ស្រេង | ១៦- ឯកឧត្តម | ហ៊ែល ចំរើន |
| ១៧- លោក | សាន ផាន់នី | ១៨- លោក | តាន់ ប៊ុនណា |
| ១៩- លោក | ជីង ប៊ុនថន | ២០- លោក | ទេព សារិ |
| ២១- លោក | ប៉ែត សំណាង | ២២- លោក | មឿង ចិស្សុត |
| ២៣- លោក | ស៊ន ឌីដេនីន | ២៤- លោក | អោម តារា |
| ២៥- លោកស្រី | ពាង សិដ្ឋា | ២៦- លោក | ហែម បណ្ណយុត្តិ |
| ២៧- លោក | អ៊ុល ណាត់ | ២៨- លោក | អ៊ឹម ស្ងួរ |
| ២៩- លោក | ផុន សម្ផស្ស | ៣០- លោក | សិរត ជេដ្ឋាភិរម្យ |
| ៣១- លោក | គីម សាន | ៣២- លោក | លី សែ |
| ៣៣- លោក | ម៉ី សុជាតិ | ៣៤- ឯកឧត្តម | ផាន់ ផល្លា |
| ៣៥- ឯកឧត្តម | ចាន់ សុភាព | ៣៦- លោក | អ៊ិន សុមេធ |
| ៣៧- លោក | គីម ផល្លា | ៣៨- ឯកឧត្តម | ទេព ភិយោរិទ្ធ |
| ៣៩- លោក | រស់ បរម | ៤០- លោក | ប៉ែន ធីរុទ្ធ |
| ៤១- លោក | ស៊ុន គីមស្រ៊ុន | ៤២- លោក | អ៊ិន អេម |
| ៤៣- លោក | ជា ផារ៉ា | ៤៤- លោក | ឡុញ ប៊ុណ្ណារ៉ា |
| ៤៥- លោក | ទេព យ៉ាត | ៤៦- លោក | មាន ជា |
| ៤៧- លោក | ញូង សុខហៃ | ៤៨- លោក | ស៊ុន ហេង |
| ៤៩- លោក | ឡាយ គីង | ៥០- លោក | និន សាម៉ាន់ |
| ៥១- លោក | ញឹក បណ្ណា | ៥២- លោក | យិន ពិសាយ |
| ៥៣- លោក | ភាណុល ចិត្រា | ៥៤- លោក | សុខ ស្រួយ |
| ៥៥- លោក | ខួន មាស | ៥៦- លោក | សាន់ សារោ |
| ៥៧- ឯកឧត្តម | កែន សម្បត្តិ | ៥៨- លោក | ឯក ចន្ថា |
| ៥៩- ឯកឧត្តម | ជូ បណ្ណៈ | ៦០- លោក | រស់ ភីរុណ |
| ៦១- លោក | នង ពិសិដ្ឋ | ៦២- ឯកឧត្តម | កៅ ថាច |
| ៦៣- លោក | តើត សុធារ៉ា | ៦៤- លោក | យត់ ប៊ុនណា |
| ៦៥- លោក | ហោ ច័ន្ទម៉ានី | ៦៦- លោក | ឌី សុបណ្ណ |
| ៦៧- លោក | ថែម ទាសនា | ៦៨- លោក | អេង រតនា |

| | | | |
|---|---|---|---|
| ៦៩- លោក | កែប ម៉ុនសួរ | ៧០- លោក | អៀង សុភាព |
| ៧១- ឯកឧត្តម | អោម ចន | ៧២- លោក | ហ៊ល សេត |
| ៧៣- លោក | វ័ត្ត មុនី | ៧៤- លោក | ហ៊ាន គ្រេង |
| ៧៥- លោក | លឹម សាន | ៧៦- លោក | ហាំង នុប្បុត្រ |
| ៧៧- ឯកឧត្តម | តឹង ម៉ាន់ថូ | ៧៨- លោក | ជូ ស្រ៊ុន |
| ៧៩- លោក | ម៉ៅ បុញ្ញខេត្ត | ៨០- លោក | ម៉ុន វ័ត្ត |
| ៨១- លោក | គីម្ហា សុផុន | ៨២- លោក | សួត ម៉ុនសាន |

ខ.គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ចំពោះ :

| | | | |
|---|---|---|---|
| ១- លោក | ស៊ុន សុទ្ធី | ២- លោក | អៀប ម៉ាន់ឌី |
| ៣- លោក | វ័ត្ត សារ៉ាត់ | ៤- លោក | វ័ត្ត ធាសនា |
| ៥- លោក | ដួង ឆារ៉ូ | ៦- លោក | ហ៊ិញ ឫទ្ធិពល |
| ៧- លោក | ប៉ោ យុទ្ធថា | ៨- លោក | ហ៊ូ គុណឧឡន៍ |
| ៩- លោក | ឈុន សិរិទ្ធ | ១០- លោក | ដារី ចេតនា |
| ១១- លោក | តូច ចាន់គ្រីស្នា | ១២- លោក | ម៉ា ស៊ីមសុរិយា |
| ១៣- លោក | ស៊ិន ច័ន្ទសិរីវុត្ថា | ១៤- លោក | លៀង អៀម |
| ១៥- លោក | គិន កោសល្ល | ១៦- លោក | អេង សេដ្ឋា |
| ១៧- លោក | ខៀវ សុខណាត | ១៨- លោក | អ៊ុំ ចន |
| ១៩- លោក | ហ៊ីវ បញ្ញាវុធ | ២០- លោក | ប៉ែន ដារ៉ាមុនី |
| ២១- លោក | ស៊ុន សុខនី | ២២- លោក | ស្រ៊ាង លីមស្រួយ |
| ២៣- លោក | ស៊ុនលី ឆារិទ្ធ | ២៤- កញ្ញា | ថោង ច័ន្ទដារី |
| ២៥- លោក | អ៊ុង ពន្យបញ្ញា | ២៦- លោក | សួប សុរិយា |
| ២៧- លោក | យូ ធី | ២៨- លោក | ហ៊ីង ច័ន្ទបូរ៉ា |
| ២៩- លោក | មាង ច័ន្ទសុផល | ៣០- លោក | លី គាយសេង |
| ៣១- លោក | ឡុញ ធីណា | ៣២- លោក | សូ សិទ្ធី |
| ៣៣- ឯកឧត្តម | សន និរន្ទ | ៣៤- លោក | តូច បុផ្ផា |
| ៣៥- លោក | ឡុង ឌិនរិទ្ធ | ៣៦- លោក | លី សារុន |
| ៣៧- លោក | បណ្ណ សំណាង | ៣៨- លោក | ជា គីមគួង |
| ៣៩- លោក | នួន សំបូរ | ៤០- លោក | ហែម ស៊ីផន |
| ៤១- លោក | ស៊ិន ណុយ | ៤២- លោក | ប៉ូ រិទ្ធី |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | |
|---|---|---|---|
| ៤៣- លោក | ឃុន ស្វគាព | ៤៤- លោក | ផាត ពិសី |
| ៤៥- លោក | ស៊ី ប្រាសិទ្ធ | ៤៦- លោក | ស៊ុំ ផល |
| ៤៧- លោក | សុខ លីណា | ៤៨- លោកស្រី | ហែម សុខា |
| ៤៩- លោក | លី សំអុល | ៥០- លោកស្រី | ទូច សុជាតិ |
| ៥១- លោក | ចាន់ ផល | ៥២- លោក | ខចំ ពេជ្រ |
| ៥៣- លោក | ម៉េង ចណ្ណា | ៥៤- លោក | ប៊ូ ច័ន្ទបូរ៉ា |
| ៥៥- លោក | ចិន រិទ្ធី | ៥៦- លោក | រស់ ម៉ារឌី |
| ៥៧- លោក | ហេង សុផល | ៥៨- លោក | យី សុភាព |
| ៥៩- លោក | ហី ម៉ារ៉ា | ៦០- លោកស្រី | ខៀវ ម៉ូលីសានី |
| ៦១- លោក | សេង ចំរើន | ៦២- លោក | ខឡូ រ៉ានី |
| ៦៣- លោក | ថុន ឧត្ដី | ៦៤- លោក | ឈឹម សំណាង |
| ៦៥- លោក | អេង ទូច | ៦៦- ឯកឧត្ដម | អ៊ុត អារ: |
| ៦៧- លោក | ម៉ៅ និទ្ធ | ៦៨- លោក | គៀត សៀមហេង |
| ៦៩- លោក | អ៊ុន មាត្រា | ៧០- ឯកឧត្ដម | ជ្រួន ថេរ៉ាម៉ាត |
| ៧១- លោក | សេត ស៊ិន | ៧២- លោក | សេត រតន: |
| ៧៣- លោក | ង ឆាយសេរីបុត្រ | ៧៤- លោក | ពេជ ច័ន្ទដារា |
| ៧៥- លោក | សរ លីមស្រ៊ី | ៧៦- លោក | គីម វិចិត្រ |
| ៧៧- លោក | ហ្លួត សម្បត្តិ | ៧៨- លោកស្រី | ឆាន់ វិរិយ៉ា |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣.៧. ១០០៤.១៥៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០*

លេខ: ១៤០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ឌិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម សេង សក្ដា

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

៣៧ល.១០០៧.១៥៨

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០

លេខ: ១៥១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១-ឯកឧត្តម ម៉ែន សំផុន ២-ឯកឧត្តម ថោង យ៉ាម៉ាន់

៣-ឯកឧត្តម ម៉ៅ សុខា ៤- ឯកឧត្តម ម៉ិត សំអុល

៥- ឯកឧត្តម រស់ សារអាន់ ៦-ឯកឧត្តម ឆួន ពិសី

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

១-ឯកឧត្តម ហួត ពៅ ២-លោក ទឹម គុសលា

៣-លោកវេជ្ជបណ្ឌិត កែវ រដ្ឋា ៤-លោក ម៉ា មិន

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១-លោក សោម ខន់អេង

ឃ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរត្ន**

ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១-លោកជំទាវ ហេង ពៅ ២-លោកជំទាវ ប៉ិច សុខច័ន្ទ

៣-លោកជំទាវ ប៊ិន គនិកា ៤-លោកជំទាវ ចាប ច័ន្ទម៉ានីកា

ង-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១- លោក គន្ធ តារាវណ្ណ ២-លោក ឡា ជីឃាង

ច-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ :

១-ឯកឧត្តម កែវ ពិសិដ្ឋ ២-លោក ចាន់ ញ៉ឹម

៣-លោក ហេង ចណ្ណា ៤-លោក អោម មុន្នីឧត្តម

៥-លោក ចាន់ រស្មី ៦-លោក សិត សិលា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣ក.៧.២០០៧.១៥៥*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០*

លេខ: ១៧៧ ច.ល

...ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

... ជិនកេន

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១:** – ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងឧទ្យានជាតិព្រះសីហនុ "រាម" ខេត្តព្រះសីហនុ លើផ្ទៃដីទំហំ **១.៦៥០ហិកតា (មួយពាន់ ប្រាំមួយរយ ហាសិបហិកតា)** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងទីតាំងតំបន់កោះថ្មី សម្រាប់ផ្តល់ជូនក្រុមហ៊ុន **HONG KONG RESEARCH INVESTMENT AND DEVELOPMENT CONSULTING GROUP CO., LTD** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យទេសចរណ៍ធម្មជាតិ ដូចមានទីតាំង និងនិយាមកា ដែលមានកំណត់តាមចំណុច **A, B, C, D, E, F** ដូចមានក្នុងផែនទីភ្ជាប់មកជាមួយ ។

**មាត្រា២:-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ


Hong Kong Asia Resources Invesment Development Consulting Group Co., Ltd
245 Ha
1650 Ha
1:50,000
Kilometers
N
S
E
W
| ID | N | X | Y |
| 1 | A | 366832 | 1155046 |
| 2 | B | 363236 | 1160369 |
| 3 | C | 364958 | 1162646 |
| 4 | D | 365031 | 1161193 |
| 5 | E | 366942 | 1161149 |
| 6 | G | 366947 | 1162116 |
| 7 | F | 367000 | 1155362 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ២៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០២ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៨/០១៣ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ៦ ទី ៨ ទី ១៤ និង ពិធីសារទី ៣ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា

ព្រះរាជាណាចក្រថៃ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់ការបង្កើត និងកិច្ចដំណើរការរបស់ **គណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន** ហៅកាត់ថា **គជសដ** (National Cross-Border Transport Facilitation Committee-NCTFC) ដើម្បីសម្រួលអោយកាន់តែសាមញ្ញនូវនីតិវិធីគ្រប់គ្រង ត្រួតពិនិត្យ និងឃ្លាំមើលលើរាល់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែននូវទំនិញ មធ្យោបាយដឹកជញ្ជូន និងអ្នកដំណើរ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន និងការអនុវត្តល្អជាអន្តរជាតិ។

**គជសដ** មានលេខាធិការដ្ឋាននៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បម្រើការងាររបស់ខ្លួន។ ភារកិច្ចរបស់លេខាធិការដ្ឋាននេះ នឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំកញ្ចប់ថវិកាមួយដោយឡែក ក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួង ដើម្បីធានានិរន្តរភាព នៃកិច្ចប្រតិបត្តិការ និងមុខងារនៃ **គជសដ** ។

## ជំពូកទី ២

## ផ្នែកទី ១

## សមាសភាព

**មាត្រា ២.-**

**គជសដ** មានសមាសភាពដូចខាងក្រោម ÷

១. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តំណាង ប្រធាន

| | |
|---|---|
| ២. ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៥. តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៦. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៩. តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១០. តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១១. តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |

## ផ្នែកទី ២

## តួនាទី និង ភារកិច្ច

**មាត្រា ៣.-**

**គជសដ** មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- សម្របសម្រួលកសាងផែនការសកម្មភាពជាយុទ្ធសាស្ត្រ ទាក់ទងនឹងការគ្រប់គ្រង និងការងារដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដើម្បីជម្រុញប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការកម្រិតខ្ពស់ក្នុងចំណោមបណ្តាក្រសួង និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ ការងារនេះ ត្រូវធានានូវតុល្យភាពរវាងការអនុវត្តបទប្បញ្ញត្តិច្បាប់ និងការសម្រួលពាណិជ្ជកម្ម ដើម្បីកាត់បន្ថយនូវពេលវេលា ការធ្វើសកម្មភាពត្រួតគ្នា និងការចំណាយលើបែបបទ ពាក់ព័ន្ធនឹងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។
- ស្រាវជ្រាវ ត្រួតពិនិត្យ និងវាយតម្លៃនូវនីតិវិធី និងបទប្បញ្ញត្តិច្បាប់ជាធរមាន ពាក់ព័ន្ធនឹងបែបបទនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន។ ក្នុងករណីចាំបាច់ ត្រូវរៀបចំនូវសេចក្តីព្រាងបទប្បញ្ញត្តិថ្មីមួយដែលមានប្រសិទ្ធភាពជាង ហើយដាក់ជូនរាជរដ្ឋាភិបាល ដើម្បីស្នើសុំការសម្រេច និងដាក់អោយអនុវត្តនូវបែបបទដឹកជញ្ជូនឆ្លងកាត់ព្រំដែនថ្មីនេះ តាមរយៈការធ្វើអោយស៊ីសង្វាក់គ្នា សាមញ្ញកម្ម និងទំនើបកម្មនូវបទប្បញ្ញត្តិទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន និងការអនុវត្តល្អជាអន្តរជាតិ ។

- សហការ សម្របសម្រួលការងារជាមួយបណ្តាក្រសួង និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានាក្នុងករណីចាំបាច់ ដើម្បីធានានូវប្រសិទ្ធភាព និងអនុលោមភាពនៃការអនុវត្តនីតិវិធីដឹកជញ្ជូនឆ្លងកាត់ព្រំដែន ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។
- ផ្សព្វផ្សាយអោយបានទូលំទូលាយដល់បុគ្គលពាក់ព័ន្ធ ជាពិសេសសហគមន៍ធុរកិច្ចអោយមានការយល់ដឹងច្បាស់លាស់អំពីនីតិវិធី និងបែបបទនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។
- បង្កើតយន្តការតាមដានប្រសិទ្ធភាព និងអនុលោមភាពនៃការអនុវត្តនីតិវិធី និងបែបបទនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។
- ធ្វើរបាយការណ៍ជាប់ជាប្រចាំអំពីកិច្ចដំណើរការ និងសកម្មភាពអនុវត្តការងារ របស់ **គជសដ** ជូនរាជរដ្ឋាភិបាល ។

## ផ្នែកទី ៣
## សិទ្ធិ

**មាត្រា ៤.-**

**គជសដ** មានសិទ្ធិដូចតទៅ÷

- បង្កើតអនុគណៈកម្មាធិការជំនាញមួយចំនួន តាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ខ្លួន ។
- អញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ ឬអ្នកឯកទេសអោយចូលរួមប្រជុំ ពិគ្រោះពិភាក្សា ផ្តល់យោបល់ និងសិក្សាស្រាវជ្រាវ អោយបានទៀងទាត់លើរាល់បញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន ។
| ៤ | ជាំ មឿន | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៥ | ថោង គន្ធា | ស | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៦ | ប្រាក់ ចិន្តា | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៧ | ម៉ុត ចាន់ថា | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៨ | ម៉ុន សាមឿន | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៩ | រ័ត្ន រតនា | ស | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១០ | សៀន ដារ៉ែន | ស | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១១ | សៀក សុផល | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១២ | សួន ស៊ីនេថ | ស | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១៣ | ហុង ម៉ៅលីម | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១៤ | ឡុង សុន្ធារិទ្ធ | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១៥ | អ៊ុច ពៅកណ្ណិកា | ស | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥៧ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**សម្រេច**

**មាត្រា ១._**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនឥស្សរជនបរទេស ចំនួន ០២រូប ដែលមានស្នាដៃល្អ ក្នុងការធ្វើសហប្រតិបត្តិការ ជួយឧបត្ថម្ភដល់ការអភិវឌ្ឍន៍ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សម្រេចបានលទ្ធផលល្អ ដូចមានរាយនាមខាងក្រោម៖

១- Dr. Ishiwata អ្នកជំនាញការស្ម័គ្រចិត្តរបស់អង្គការ JICA

២- Mr. Wolfgang Moller ប្រធានអង្គការ DED

**មាត្រា ២._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក Jan Lam ទីប្រឹក្សាជាន់ខ្ពស់ ជនជាតិហូឡង់ ផ្នែកឡជីវឧស្ម័ន/ថាមពលកកើតឡើងវិញ នៃអង្គការ SNV ដែលមានស្នាដៃល្អ ក្នុងការធ្វើសហប្រតិបត្តិការជួយអភិវឌ្ឍន៍ ផ្នែកឡជីវឧស្ម័ន/ថាមពលកកើតឡើងវិញ កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ និង កម្មវិធីបច្ចេកទេស ជាមួយនាយកដ្ឋាន ផលិតកម្ម និងបសុព្យាបាល សម្រេចបានលទ្ធផលល្អ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៤ . អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

### សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូននាយទាហាន និង មន្ត្រីរាជការ ចំនួន០៤រូប នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានស្នាដៃល្អក្នុងការជួយកសាងអង្គភាពតំបន់ប្រតិបត្តិការសឹករងស្ទឹងត្រែង និងកិច្ចសហប្រតិបត្តិការល្អ ជាមួយកងយោធពលខេមរភូមិន្ទ កន្លងមក ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១ | លោក | **វ៉ តឹនថាយ** | VO TAN THAI | ប្រធាន មន្ទីរផែនការ និង វិនិយោគខេត្ត ខាញ់ហ័រ |
| ២ | លោក | **ង្វៀង វ៉ាន់យែ** | NGUYEN VAN DE | ប្រធាន មន្ទីរស្ថាបនា ខេត្ត ខាញ់ហ័រ |
| ៣ | លោកស្រី | **វ៉ធី ធៀតណា** | VO THI TUYET NA | ប្រធាន មន្ទីរហិរញ្ញវត្ថុ ខេត្ត ខាញ់ហ័រ |
| ៤ | វរសេនីយ៍ទោ | **ង្វៀន ឌិញហ្វុក** | NGUYEN DINHP HU | ប្រធាន មន្ទីរវិស្វកម្មយោធា ខេត្ត ខាញ់ហ័រ |

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៥៥ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ . បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **លន់ គីមឃួន** ជា ប្រធាននាយកដ្ឋាន អាហ្វ្រិក មជ្ឈឹមបូព៌ា នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ០៥ សសរ.**

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលនិងរៀបចំការចងសម្ព័ន្ធមេត្រីភាពរវាងអង្គភាពកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន-អង្គភាពស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ ០៧ សសរ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១០ ស្តីពីការកែសម្រួល និងរៀបចំការចងសម្ព័ន្ធមេត្រីភាពរវាងអង្គភាពកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន-អង្គភាពស៊ីវិល
- យោងតាមសំណូមពរនិងតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១**: ត្រូវបានកែសម្រួលការរៀបចំសម្ព័ន្ធភាពនៃយោធភូមិភាគទី ២ ដែលចែងក្នុងប្រការ ១ នៃសេចក្តីសម្រេច លេខ ០៧ សសរ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១០ ស្តីពីការកែសម្រួលនិងរៀបចំការចងសម្ព័ន្ធមេត្រីភាពរវាងអង្គភាពកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន-អង្គភាពស៊ីវិល ដូចខាងក្រោម៖

**យោធភូមិភាគ ២**:

- វរសេនាតូចព្រំដែន ២០១, ២០២, ២០៣, ២០៤ សម្ព័ន្ធមេត្រីជាមួយ
  - ក្រសួងយុត្តិធម៌
  - ក្រុមហ៊ុនអភិវឌ្ឍន៍កោះពេជ្រ
- កងពលតូចលេខ ២១ សម្ព័ន្ធមេត្រីជាមួយ
  - ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
  - ក្រុមហ៊ុន AZ

**ប្រការ ២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ អគ្គនាយកភស្តុភារ និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន-អង្គភាព មេបញ្ជាការអង្គភាពនិងគ្រប់ក្រសួង ស្ថាប័ន អង្គភាព ដែលមានចែងក្នុងប្រការ ១ និងមានការពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០១០




**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩សសរ

# សេចក្ដីសម្រេច

## ស្ដីពីការកែសម្រួលនិងរៀបចំការចងសម្ព័ន្ធមេត្រីភាព

## រវាងអង្គភាពកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន-អង្គភាពស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណូមពរនិងតម្រូវការចាំបាច់នៃការងារ

## សម្រេច

ប្រការ ១ : ត្រូវបានកែសម្រួលនិងរៀបចំឡើងវិញនូវការចងសម្ព័ន្ធមេត្រីភាពរវាងអង្គភាពកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន-អង្គភាពស៊ីវិល ដូចមានខាងក្រោម :

I – អង្គភាពកងទ័ព :

**យោធភូមិភាគ ១ :**

- ទីបញ្ជាការយោធភូមិភាគសម្ព័ន្ធមេត្រីជាមួយ - ក្រសួងសង្គមកិច្ច ការងារ អតីតយុទ្ធជន និងយុវនីតិសម្បទា
  - ក្រុមហ៊ុនចំការកៅស៊ូចំការអណ្តូង

- វរសេនាធំលេខ ៤២ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងបរិស្ថាន
  - ក្រុមហ៊ុនចំការកៅស៊ូពាមជាំង

- វរសេនាតូច ១០១ ,១០២, ១០៣ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងកិច្ចការនារី
  - ក្រុមហ៊ុនទ្រីភាព

**យោធភូមិភាគ ២ :**

- វរសេនាតូចព្រំដែន ២០១,២០២,២០៣,២០៤ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងយុត្តិធម៌
  - ក្រុមហ៊ុនអភិវឌ្ឍន៍កោះពេជ្រ
- កងពលតូចលេខ ២៧ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
  - ក្រុមហ៊ុន AZ

**យោធភូមិភាគ ៣ :**

- ទីបញ្ជាការយោធភូមិភាគសម្ព័ន្ធមេត្រីជាមួយ - ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
  - ក្រុមហ៊ុន អានកូ

- វរសេនាតូចព្រំដែនលេខ ៣០១ , ៣០២, ៣០៣ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
  - ក្រុមហ៊ុនកាស៊ីណូ លី យ៉ុងផាត់ ខេត្តកោះកុង

- វរសេនាតូច ៣១៣ សម្ព័ន្ធមេត្រីជាមួយ - កំពង់ផែស្វយ័តក្រុងភ្នំពេញ
  - ក្រុមហ៊ុនចំការអំពៅ លី យ៉ុងផាត់ ខេត្តកំពង់ស្ពឺ

**យោធភូមិភាគ ៤ :**

- ទីបញ្ជាការយោធភូមិភាគ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងទេសចរណ៍
  - អាជ្ញាធរអប្សរា
  - ក្រុមហ៊ុនទូរស័ព្ទ Mobitel 012

- កងពលតូចថ្មើរជើងលេខ ៤១ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងប្រៃណីយ៍ និងទូរគមនាគមន៍
  - ក្រុមហ៊ុនចំការកៅស៊ូជុប

- កងពលតូចថ្មើរជើងលេខ ៤២ សម្ព័ន្ធមេត្រីជាមួយ - អគ្គិសនីកម្ពុជា
  - ក្រុមហ៊ុនកាស៊ីណូ លីយ៉ុងផាត់ អូរស្មាច់

- កងការពារព្រំដែន ៤០១ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - វិទ្យុ និងទូរទស្សន៍បាយ័ន

- កងការពារព្រំដែន ៤០២ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងសាធារណការ និងដឹកជញ្ជូន
  - ទូរទស្សន៍ CTN

- កងការពារព្រំដែន ៤០៣ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងសាធារណការ និងដឹកជញ្ជូន
  - សណ្ឋាគារកាំបូឌីយ៉ាណា

- កងការពារព្រំដែន ៤០៤ សម្ព័ន្ធមេត្រីជាមួយ - ក្រុមទីប្រឹក្សា ជំនួយការ និងខុទ្ទកាល័យនាយករដ្ឋមន្ត្រី និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
  - ភូមិវប្បធម៌កាណាឌីយ៉ា ខេត្តសៀមរាប

- **កងពលធំអន្តរាគមន៍លេខ ២ :**
  - ទីបញ្ជាការកងពលធំ សម្ព័ន្ធមេត្រីជាមួយ - អគ្គនាយកដ្ឋានគយ និងរដ្ឋាករ
    - ក្រុមហ៊ុនតេលា
  - កងពលតូចលេខ ៤ សម្ព័ន្ធមេត្រីជាមួយ - សាលាខេត្តព្រះសីហនុ
    - ក្រុមហ៊ុនចំការកៅស៊ូមេមត់
  - កងពលតូចលេខ ៥ សម្ព័ន្ធមេត្រីជាមួយ - សាលាខេត្តសៀមរាប
    - មជ្ឈមណ្ឌលកំសាន្ត ស៊្សាក
  - កងពលតូចលេខ ៦ សម្ព័ន្ធមេត្រីជាមួយ - សាលាខេត្តកំពង់ចាម
    - ឧកញ៉ា ឡាវម៉េងឃីន និងលោកជំទាវ
    - ឧកញ៉ា ស៊ឹគង់ ទ្រីវ និងលោកជំទាវ
    - ឧកញ៉ា វិញ ហ៊ួរ និងលោកជំទាវ

- **កងពលធំអន្តរាគមន៍លេខ ៣ :**
  - ទីបញ្ជាការកងពលធំ សម្ព័ន្ធមេត្រីជាមួយ - ទីស្តីការគណៈរដ្ឋមន្ត្រី
    - ក្រុមហ៊ុនចំការកៅស៊ូក្រែក
  - កងពលតូចអន្តរាគមន៍លេខ ៧ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងការងារបណ្តុះបណ្តាល វិជ្ជាជីវៈ
    - ក្រុមហ៊ុន ម៉ែន សារុន

- កងពលតូចអន្តរាគមន៍លេខ ៨ សម្ព័ន្ធមេត្រីជាមួយ - អង្គភាពរដ្ឋករទឹកស្វយ័តភ្នំពេញ
  - ធនាគារ ANZ Royal
- កងពលតូចអន្តរាគមន៍លេខ ៩សម្ព័ន្ធមេត្រីជាមួយ - សាលារាជធានីភ្នំពេញ
  - ក្រុមហ៊ុន NCX Honda
  - ក្រុមហ៊ុនញ៉ឹក ផន ហ្គ្រុប

**យោធភូមិភាគ ៥ :**

- ទីបញ្ជាការយោធភូមិភាគ សម្ព័ន្ធមេត្រីជាមួយ - រដ្ឋបាលជលផល
  - ក្រុមហ៊ុនសូគីម៉ិច
- កងពលតូចថ្មើរជើងលេខ ៥១ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងសុខាភិបាល
  - សណ្ឋាគារ Sokha Resort & Hotel
- កងពលតូចថ្មើរជើងលេខ ៥២ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងអភិវឌ្ឍន៍ជនបទ
  - ឧកញ៉ា សំ អាង និងលោកជំទាវ ឈុន លាង
- កងពលតូចថ្មើរជើងលេខ ៥៣ សម្ព័ន្ធមេត្រីជាមួយ- រតនាគារជាតិ
  - ឧកញ៉ា សំ អាង និងលោកជំទាវ ឈុន លាង
- កងពលតូចអន្តរាគមន៍លេខ ១៤ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងឧស្សាហកម្ម ថាមពល និងរ៉ែ
  - ធនាគារកាណាឌីយ៉ា
- កងការពារព្រំដែនលេខ ៥០១ សម្ព័ន្ធមេត្រីជាមួយ- អគ្គនាយកដ្ឋានពន្ធដារ
  - ក្រុមហ៊ុន សំ អាង និងលោកជំទាវ ឈុន លាង
- កងការពារព្រំដែនលេខ ៥០២ សម្ព័ន្ធមេត្រីជាមួយ- កាំសាប
  - ផ្សារសូរិយ៉ា
- កងការពារព្រំដែនលេខ ៥០៣ សម្ព័ន្ធមេត្រីជាមួយ- អគ្គនាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម
  - ផ្សារសុវណ្ណា
- កងការពារព្រំដែនលេខ ៥០៤ សម្ព័ន្ធមេត្រីជាមួយ- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
  - សណ្ឋាគារឯករាជ្យ ( ក្រុងព្រះសីហនុ )
- កងពលលេខ ១១ សម្ព័ន្ធមេត្រីជាមួយ - ក្រសួងពាណិជ្ជកម្ម
  - ក្រុមហ៊ុនចំការកៅស៊ូបឹងកេត

• មូលដ្ឋានជើងទឹករាម និងបណ្តាកោះ សម្ព័ន្ធមេត្រីជាមួយ- កំពង់ផែស្វយ័តក្រុងព្រះសីហនុ
- ក្រុមហ៊ុនមិត្តហ្វូន ០៩៧

• កងពលលេខ ៣១ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រុមហ៊ុន មិត្តហ្វូន ០៩៧

• បញ្ជាការដ្ឋានកងរថក្រោះ សម្ព័ន្ធមេត្រីជាមួយ- កំពង់ចម្លងអ្នកលឿង
- ក្រុមហ៊ុនវត្ត សុភាព

• កងពលតូចលេខ ១ សម្ព័ន្ធមេត្រីជាមួយ- ធនាគារជាតិកម្ពុជា
- ក្រុមហ៊ុន Attwood

• បញ្ជាការដ្ឋានកងកាំភ្លើងធំ សម្ព័ន្ធមេត្រីជាមួយ - អគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន
- ធនាគារពាណិជ្ជកម្មក្រៅប្រទេស

• បញ្ជាការដ្ឋានកងបញ្ជូនសារ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងធម្មការ និងសាសនា
- ក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប

• បញ្ជាការដ្ឋានកងការពារអាកាស សម្ព័ន្ធមេត្រីជាមួយ- រដ្ឋបាលព្រៃឈើ
- ក្រុមហ៊ុន ថារី ពាណិជ្ជ

**យោធភូមិភាគពិសេស :**

• កងការពារព្រំដែនលេខ ៦០១ សម្ព័ន្ធមេត្រីជាមួយ- សាលាខេត្តកណ្តាល
- ក្រុមហ៊ុន ហេង អភិវឌ្ឍន៍

• កងពលតូចថ្មើរជើងល្បឿនលឿន ៩១១សម្ព័ន្ធមេត្រីជាមួយ- ក្រសួងអប់រំយុវជន និងកីឡា
- ក្រុមហ៊ុន ស៊ុយ សុផាន

II - **អង្គភាពកងរាជអាវុធហត្ថលើផ្ទៃប្រទេស :**

**ភូមិភាគ ៤ :**

• វរសេនាតូចលេខ ១០៥ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- វិទ្យុ និងទូរទស្សន៍បាយ័ន

• វរសេនាតូចលេខ ៧៩៣ សម្ព័ន្ធមេត្រីជាមួយ- សាលារាជធានីភ្នំពេញ
- ក្រុមហ៊ុន Mobitel 012

• វិរសេនាតូចលេខ ៧៩៥ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រុមហ៊ុន តេលា

• វិរសេនាតូចលេខ ៩០៥សម្ព័ន្ធមេត្រីជាមួយ- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ធនាគារ ANZ Royal

• វិរសេនាតូចលេខ ៧០២ សម្ព័ន្ធមេត្រីជាមួយ- អគ្គិសនីកម្ពុជា
- ក្រុមហ៊ុន លី យ៉ុងផាត់

**ភូមិភាគ ៥**

• វិរសេនាតូចលេខ ៨០៧ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងពតិមាន
- ក្រុមហ៊ុន OMC

• វិរសេនាតូចលេខ ៩១១សម្ព័ន្ធមេត្រីជាមួយ- ក្រសួងពតិមាន
- ធនាគារពាណិជ្ជកម្មក្រៅប្រទេស

• វិរសេនាតូចលេខ ៨៩១ សម្ព័ន្ធមេត្រីជាមួយ- សាលាខេត្តបន្ទាយមានជ័យ
- ក្រុមហ៊ុន លី ឈួង

• វិរសេនាតូចលេខ ៨១៥ សម្ព័ន្ធមេត្រីជាមួយ- សាលាខេត្តបន្ទាយមានជ័យ
- ធនាគារកាណាឌីយ៉ា

• វិរសេនាតូចលេខ ៨១៧ សម្ព័ន្ធមេត្រីជាមួយ- សាលាខេត្តបាត់ដំបង
- ក្រុមហ៊ុន សូគីម៉ិច

• វិរសេនាតូចលេខ ៨១៩ សម្ព័ន្ធមេត្រីជាមួយ- សាលាខេត្តបាត់ដំបង
- ក្រុមហ៊ុន សូគីម៉ិច

• វិរសេនាតូចលេខ ៨២១ សម្ព័ន្ធមេត្រីជាមួយ- សាលាខេត្តប៉ៃលិន
- ក្រុមហ៊ុន ជីវ ឡេង

• វិរសេនាតូចលេខ ៨២៣ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងផែនការ
- ក្រុមហ៊ុន ណារី ហ្គាមិន

• វិរសេនាតូចលេខ ៣១០ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងផែនការ
- ក្រុមហ៊ុន សោម សុផល

• វរសេនាតូចលេខ ៨២៥ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងឧស្សាហកម្ម ថាមពល និងរ៉ែ
- ក្រុមហ៊ុន ទ្រី ភាព

**ភូមិភាគ ៣ :**

• វរសេនាតូចលេខ ៨២៧ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងទំនាក់ទំនងព្រឹទ្ធភា រដ្ឋសភា និងអធិការកិច្ច
- ក្រុមហ៊ុន ម៉ុង ឫទ្ធី

• វរសេនាតូចលេខ ២៦៩ សម្ព័ន្ធមេត្រីជាមួយ- ក្រសួងទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច
- ក្រុមហ៊ុន គូ ហ៊ួឡុង

ប្រការ ២ : សេចក្តីសម្រេចលេខ ១៥ សសរ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥ និងសេចក្តីសម្រេចលេខ ២៣ សសរ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៥ សេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១០ និងសេចក្តីសំរេចលេខ ០៨ សសរ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១០ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ អគ្គនាយកភស្តុភារ និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន-អង្គភាព មេបញ្ជាការអង្គភាពនិងគ្រប់ក្រសួង ស្ថាប័ន អង្គភាព ដែលមានចែងក្នុងប្រការ ១ និងមានការពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១០

គណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៩ សសរ

## សេចក្តីសម្រេច

**ស្តីពីការនិរាករណ៍កិច្ចសន្យាលក់- ទិញអគ្គិសនី រវាងអគ្គិសនីកម្ពុជានិងអាជ្ញាធរអប្សរា សំរាប់យកទៅចែកចាយ នៅតំបន់ ១ តំបន់ ២ និងនៅក្នុងបុរីទេសចរណ៍ និងវប្បធម៌ ខេត្តសៀមរាប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ និងកិច្ចព្រមព្រៀងផ្ទេរសិទ្ធិ និងកាតព្វកិច្ចនៃកិច្ចសន្យាលក់- ទិញអគ្គិសនីពីក្រុមហ៊ុនអគ្គិសនីកម្ពុជា រវាងអាជ្ញាធរអប្សរា និងក្រុមហ៊ុន ស៊ូជីង អេឡិចត្រូនិក ( Sou Ching Electronic Co.,Ltd ) ដើម្បីធ្វើការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ ១ តំបន់ ២ និងនៅក្នុងបុរីទេសចរណ៍ និងវប្បធម៌ខេត្តសៀមរាប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរនិងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** : និរាករណ៍កិច្ចសន្យាលក់- ទិញអគ្គិសនី រវាងអគ្គិសនីកម្ពុជា និងអាជ្ញាធរអប្សរាសំរាប់យកទៅចែកចាយនៅតំបន់ ១ តំបន់ ២ និងនៅក្នុងបុរីទេសចរណ៍ និងវប្បធម៌ខេត្តសៀមរាប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ និងកិច្ចព្រមព្រៀងផ្ទេរសិទ្ធិ និងកាតព្វកិច្ចនៃកិច្ចសន្យាលក់- ទិញអគ្គិសនីពីក្រុមហ៊ុនអគ្គិសនីកម្ពុជា រវាងអាជ្ញាធរអប្សរា និងក្រុមហ៊ុន ស៊ូជីង អេឡិចត្រូនិក ( Sou Ching Electronic Co.,Ltd ) ដើម្បីធ្វើការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ ១ តំបន់ ២ និងនៅក្នុងបុរីទេសចរណ៍ និងវប្បធម៌ខេត្តសៀមរាប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ។

**ប្រការ ២** : ប្រគល់ភារកិច្ចជូនអគ្គិសនីកម្ពុជាគ្រប់គ្រងការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ ១ តំបន់ ២ និងនៅក្នុងបុរីទេសចរណ៍ និងវប្បធម៌ ខេត្តសៀមរាប យ៉ាងយូរបំផុតរយៈពេល ១ សប្តាហ៍ បន្ទាប់ពីថ្ងៃចេញសេចក្តីសំរេចនេះ ។

**ប្រការ ៣ :** អគ្គិសនីកម្ពុជាត្រូវចាប់ផ្តើមវិនិយោគយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាពក្នុងវិស័យផ្គត់ផ្គង់ និងចែកចាយអគ្គិសនីនៅក្នុងតំបន់ខាងលើ ។

**ប្រការ ៤ :** បង្កើតគណៈកម្មការមួយ ដើម្បីធ្វើការវាយតម្លៃលើការចំណាយនៃការវិនិយោគរបស់ក្រុមហ៊ុន ស៊ូជីង អេឡិច-ត្រូនិកកន្លងមកដែលមាន ÷

- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាប្រធាន
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គស្នងការរងនគរបាលជាតិ ១ រូប
- មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- អគ្គនាយកអាជ្ញាធរអប្សរា
- ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា
- ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា
- អភិបាល នៃគណៈអភិបាលខេត្តសៀមរាប
- តំណាងក្រុមហ៊ុន ស៊ូជីង អេឡិចត្រូនិក

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០២៥ សហវ.ប្រក

ទទួល ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ 2010

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និង អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- បានឃើញ ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ស្តីពីកិច្ចសន្យា និងកាទទួលខុសត្រូវក្រៅកិច្ចសន្យា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៨
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង អនុក្រឹត្យលេខ ២០អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងការកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA

- បានឃើញអនុក្រឹត្យលេខ ១៣៤.អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៩ លើលិខិតលេខ ១១៦៨ សហវ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ លើលិខិតលេខ ០៨២ សហវ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ស្តីពីការគ្រប់គ្រង ការត្រួតពិនិត្យ និងការផ្តល់អាជ្ញាប័ណ្ណអាជីវកម្ម ទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- បានឃើញ ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល ការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

### ប្រការ១: គោលដៅ

ប្រកាសនេះមានគោលដៅអនុវត្តចំពោះប្រតិបត្តិការខ្ចីប្រាក់ដែលមានវត្ថុដាក់ធានាជាទ្រព្យផ្សេងៗ នៅកន្លែង អាជីវកម្មស្របច្បាប់ណាមួយដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រៅពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។

### ប្រការ២: គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់នូវវិធានការជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់គ្រងអាជីវកម្មដើម្បី :

-កែលំអ និងតំរង់ទិសដល់ប្រតិបត្តិការអាជីវកម្ម ឱ្យអនុវត្តបានត្រឹមត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ។

-ការដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានទ្រព្យសម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗ ធ្វើឡើងតាម រយៈកន្លែងអាជីវកម្មដែលទទួលបានអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការគ្រប់គ្រង និង កាត់បន្ថយបាននូវហានិភ័យមួយចំនួនដែលអាចកើតមានឡើងជាយថាហេតុ ។

-សំរួលដល់វិនិយោគិន និងប្រជាពលរដ្ឋដែលមានបំណងដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានទ្រព្យ សម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗឱ្យទទួលបាននូវសេវាល្អប្រសើរ និងតំលៃមួយសមស្របតាមថ្លៃទីផ្សារ ។

-បង្កើនការគ្រប់គ្រងការពារសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមតាមរយៈការត្រួតពិនិត្យ ការពារ អំពើចោរកម្មទ្រព្យសម្បត្តិ ។

-បង្កើនភាពជឿទុកចិត្តដល់អតិថិជន អាជីវករ និងអ្នកទិញទ្រព្យពីកន្លែងអាជីវកម្ម

-ធានាការទូទាត់ និងរក្សាទុកទ្រព្យដែលអាចទទួលយកបានរវាងអតិថិជន និងអាជីវករ

-បង្កើនប្រាក់ចំណូលជាតិតាមរយៈការយកពន្ធអាករ និងការបង់ថ្លៃសេវាផ្សេងៗ

## ប្រការ៣: និយមន័យ

- **"ក្រសួង"** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- **"អាជីវកម្ម"** សំដៅដល់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ឬ អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។

- **"អាជីវករ"** សំដៅដល់អ្នកទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន ដែលជារូបវ័ន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរដែលបានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់ ដើម្បីប្រកបអាជីវកម្មឱ្យខ្ចីប្រាក់ដោយយកទ្រព្យផ្សេងៗដាក់ធានា។

- **"បញ្ចាំ"** សំដៅទៅលើការណ៍ដែលអតិថិជនដាក់នូវចលនវត្ថុ ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ ឬឯកសារផ្សេងៗ ជាមួយអាជីវករ ដើម្បីធានាដល់ការទូទាត់សងប្រាក់កម្ចី និងការប្រាក់។

- **"ប្រាតិភោគដោយអនុប្បទាន"** សំដៅទៅលើការណ៍ដែលអតិថិជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ជាមួយអាជីវករ ដើម្បីធានាដល់ការទូទាត់សងប្រាក់កម្ចី និងការប្រាក់។

- **"អតិថិជន"** សំដៅដល់អ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានដែលជា រូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យសម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗទៅដាក់ធានាជាមួយនឹងអាជីវករ ដើម្បីទទួលបានប្រាក់កម្ចី ។

- **"កិច្ចសន្យា"** សំដៅដល់កិច្ចសន្យាបញ្ចាំ ឬកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ដែលធ្វើឡើងរវាងអតិថិជនជាមួយនឹងអាជីវករលើការដាក់ទ្រព្យធានា ។

- **"កន្លែងអាជីវកម្ម"** សំដៅដល់ហាងទទួលបញ្ចាំ ឬក្រុមហ៊ុនទទួលបញ្ចាំ ឬហាងទទួលប្រាតិភោគដោយអនុប្បទាន ឬក្រុមហ៊ុនទទួលប្រាតិភោគដោយអនុប្បទានរួមមាន : អាគារ លំនៅដ្ឋាន ឃ្លាំង ឬទីកន្លែង អាជីវកម្មផ្សេងៗទៀតដែលត្រូវបានជ្រើសរើសដើម្បីធ្វើជាទីកន្លែងសម្រាប់ធ្វើអាជីវកម្ម ។

- **"ទ្រព្យ"** សំដៅដល់ទ្រព្យបញ្ចាំរួមមានចលនវត្ថុ ឬឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ និងឯកសារផ្សេងៗ ដែលជាកម្មវត្ថុយកមកដាក់បញ្ចាំ និង សំដៅដល់ទ្រព្យប្រាតិភោគដោយអនុប្បទានដែលមានចលនវត្ថុជាកម្មវត្ថុយកមកដាក់ធ្វើប្រាតិភោគដោយអនុប្បទាន។

- **"អាជ្ញាប័ណ្ណ"** សំដៅដល់លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលបញ្ចាំ ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- **"លោះ"** គឺជាការទទួលយកមកវិញនូវទ្រព្យ ដែលបានមកពីការសងប្រាក់កម្ចីរួមទាំងការប្រាក់របស់អតិថិជន ជូនទៅអាជីវករដូចដែលមានចែងនៅក្នុងកិច្ចសន្យា។

## ប្រការ៤: ការអនុញ្ញាតធ្វើអាជីវកម្ម

គ្មានរូបវ័ន្តបុគ្គល ឬនីតិបុគ្គលណាម្នាក់អាចធ្វើអាជីវកម្មបានទេ ប្រសិនបើគ្មានអាជ្ញាប័ណ្ណពីក្រសួង។

## ប្រការ៥: ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ

រូបវ័ន្តបុគ្គល ឬនីតិបុគ្គលទាំងអស់ដែលកំពុងធ្វើអាជីវកម្ម ឬមានបំណងចង់ធ្វើអាជីវកម្មត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណនៅក្រសួង ។

ពាក្យស្នើសុំអាជ្ញាប័ណ្ណ ត្រូវបានរៀបចំជូនដោយនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ប្រការ៦: ថ្លៃអាជ្ញាប័ណ្ណ

អាជីវករត្រូវបង់ថ្លៃអាជ្ញាប័ណ្ណដូចខាងក្រោម :

សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ

- -អាជ្ញាប័ណ្ណថ្មីចំនួន ២.០០០.០០០ រៀល (ពីរលានរៀល)
- -បន្តអាជ្ញាប័ណ្ណចំនួន ២.០០០.០០០ រៀល (ពីរលានរៀល)
- -អាជ្ញាប័ណ្ណសាខាចំនួន ១.០០០.០០០ រៀល (មួយលានរៀល)
- -បន្តអាជ្ញាប័ណ្ណសាខាចំនួន ១.០០០.០០០ រៀល (មួយលានរៀល)

សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

- -អាជ្ញាប័ណ្ណថ្មីចំនួន ១.០០០.០០០ រៀល (មួយលានរៀល)
- -បន្តអាជ្ញាប័ណ្ណចំនួន ១.០០០.០០០ រៀល (មួយលានរៀល)
- -អាជ្ញាប័ណ្ណសាខាចំនួន ៥០០.០០០ រៀល (ប្រាំសែនរៀល)
- -បន្តអាជ្ញាប័ណ្ណសាខាចំនួន ៥០០.០០០ រៀល (ប្រាំសែនរៀល)

អាជីវករត្រូវបង់ប្រាក់ថ្លៃអាជ្ញាប័ណ្ណដូចមានចែងខាងលើទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារជាតិនៃកម្ពុជា តាមដីការអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រការ៧: សុពលភាព និងការបន្តសុពលភាពអាជ្ញាប័ណ្ណ

អាជ្ញាបណ្ណ័មានសុពលភាពរយៈពេល ០១ ឆ្នាំ (មួយឆ្នាំ) គិតចាប់ពីថ្ងៃចុះហត្ថលេខា ។

អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពឱ្យបាន ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុនពេលអាជ្ញាប័ណ្ណនោះអស់សុពលភាព ។

ក្រសួងមានសិទ្ធិបន្តអាជ្ញាប័ណ្ណដោយមានដាក់ ឬមិនមានដាក់លក្ខខណ្ឌ ឬមិនបន្តអាជ្ញាប័ណ្ណប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវណាមួយដែលក្រសួងបានកំណត់ ។

ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណមិនបន្តសុពលភាពអាជ្ញាប័ណ្ណ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដោយភ្ជាប់មកជាមួយ នូវឯកសារពាក់ព័ន្ធព្រមទាំងបញ្ជាក់អំពីមូលហេតុអោយបានត្រឹមត្រូវមកក្រសួងក្នុងរយៈពេល ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុន ។

## ប្រការ៨: លក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណ

ក្រសួងនឹងផ្តល់អាជ្ញាប័ណ្ណ ជូនដល់អាជីវករទាំងឡាយណាដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម :

-ជារូបវ័ន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ហើយមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ឬនីតិបុគ្គលមានសញ្ជាតិខ្មែរដែលបានបំពេញបែបបទ និងចុះបញ្ជីត្រឹមត្រូវតាមច្បាប់

-លិខិតថ្កោលទោស ឬលិខិតបញ្ជាក់កិរិយាមាយាទដែលចេញដោយក្រសួងយុត្តិធម៌ ឬពីអាជ្ញាធរពាក់ព័ន្ធ

-បានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់នៅក្រសួងពាណិជ្ជកម្ម

-មានអាស័យដ្ឋានស្នាក់នៅច្បាស់លាស់ក្នុងព្រះរាជាណាចក្រកម្ពុជា

-ត្រូវបង្ហាញពីកន្លែងសុវត្ថិភាពដើម្បីធានាថែរក្សា និងការពារការខូចខាត ឬការបាត់បង់ទ្រព្យ

-សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំត្រូវមានដើមទុនអាជីវកម្មអប្បបរមាចំនួន ៨០.០០០.០០០ រៀល (ប៉ែតសិបលានរៀល) និងដាក់ប្រាក់តំកល់ចំនួន ១០% នៃដើមទុនអាជីវកម្ម ឬប្រាក់តំកល់អតិបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) ទៅក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ត្រូវមានដើមទុនអាជីវកម្មអប្បបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) និងដាក់ប្រាក់តំកល់ចំនួន ១០% នៃដើមទុនអាជីវកម្ម ឬប្រាក់តំកល់អតិបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) ទៅក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-អាជីវករអាចដកប្រាក់តំកល់ខាងលើមកវិញបាន លុះត្រាតែមានការអនុញ្ញាតិពីក្រសួងដូចដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-ត្រូវមានលិខិតបញ្ជាក់អាស័យដ្ឋានកន្លែងអាជីវកម្មអោយបានច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋាន

-មានកិរិតវប្បធម៌យ៉ាងតិចពីថ្នាក់បរិញ្ញាបត្រ ឬប្រហាក់ប្រហែលផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ឬនីតិសាស្ត្រ ឬវិញ្ញាបនបត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងផ្នែកអាជីវកម្ម ឬធ្លាប់បំរើការងារផ្នែកនេះពីមុន ។

-មានសមត្ថភាពក្នុងការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពទាំងការនិយាយ ការសរសេរ និងមានសមត្ថភាពក្នុងការរៀបចំរបាយការណ៍ដែលមានទំរង់បែបបទត្រឹមត្រូវ ។

-បង្ហាញពីម្ចាស់ភាគហ៊ុន នាយកក្រុមហ៊ុន អ្នកគ្រប់គ្រងផ្នែកផ្សេងៗ និងឈ្មោះបុគ្គលិកដែលបំរើការងារនៅក្នុងកន្លែងអាជីវកម្មអោយបានច្បាស់លាស់ ។

-បានបង់ថ្លៃអាជ្ញាប័ណ្ណដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ

-ភ្ជាប់គំរូស្លាកសញ្ញា និងត្រារបស់កន្លែងអាជីវកម្ម ព្រមទាំងហត្ថលេខារបស់អ្នកកាន់អាជ្ញាប័ណ្ណ

ការកំណត់លក្ខខណ្ឌផ្សេងទៀត អាចនឹងតម្រូវបន្ថែមដោយក្រសួង ។

## ប្រការ៩: លក្ខខណ្ឌនៃការមិនផ្តល់អាជ្ញាប័ណ្ណ

ក្រសួងមិនផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មជូនអ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទាំងឡាយណាដែលស្ថិតនៅក្នុងលក្ខខណ្ឌដូចខាងក្រោម :

-ផ្តល់ព័ត៌មានមិនពិតចំពោះចំណុចណាមួយដែលមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ

-មិនបានផ្តល់ព័ត៌មានដែលខ្វះចន្លោះណាមួយដែលមានចែងក្នុងប្រការ៨ នៃប្រកាសនេះមកអោយក្រសួងក្នុង

រយៈពេល ១៥ថ្ងៃ (ដប់ប្រាំថ្ងៃ) បន្ទាប់ពីមានការស្នើសុំជាលាយលក្ខអក្សរពីក្រសួងដល់អ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ។

## ប្រការ១០: ភារកិច្ចនិងកាតព្វកិច្ចនៃអាជីវករ (អ្នកកាន់អាជ្ញាប័ណ្ណ)

អ្នកកាន់អាជ្ញាប័ណ្ណមានកាតព្វកិច្ចដូចតទៅ :

១-ត្រូវអនុវត្តគោរពតាមរាល់លិខិតបទដ្ឋានផ្សេងៗដែលចេញដោយក្រសួង

២-ត្រូវការពារ និងលើកកំពស់អត្ថប្រយោជន៍អតិថិជនរបស់ខ្លួន ហើយកាតព្វកិច្ចចំបងមួយទៀតគឺមិនត្រូវគេចវេសពីការទទួលខុសត្រូវចំពោះភាគីដទៃទៀតដែលពាក់ព័ន្ធក្នុងកិច្ចការអាជីវកម្មរបស់ខ្លួនឡើយ

៣-ត្រូវមានស្លាកសញ្ញាអាជីវកម្មនៅពីមុខកន្លែងធ្វើអាជីវកម្ម ហើយអាជ្ញាប័ណ្ណត្រូវរក្សានៅក្នុងហាង ឬក្រុមហ៊ុនដែលកំពុងប្រកបអាជីវកម្ម និងត្រូវដាក់តាំងនៅកន្លែងដែលងាយមើលឃើញ

៤-ត្រូវមានសៀវភៅចុះបញ្ជីទ្រព្យ សៀវភៅលោះទ្រព្យ និងសៀវភៅចំណូលចំណាយប្រចាំខែ និងឯកសារផ្សេងៗដែលពាក់ព័ន្ធ ។ ដោយទំរង់នៃសៀវភៅទាំងនោះនឹងមានបញ្ជាក់នៅក្នុងសៀវភៅបន្ទុក

៥-ត្រូវចេញកិច្ចសន្យាឱ្យទៅអតិថិជន ។ ទំរង់នៃកិច្ចសន្យានឹងមានបញ្ជាក់នៅក្នុងសៀវភៅបន្ទុក

៦-ត្រូវសរសេរជាលាយលក្ខអក្សរ ដើម្បីជៀសវាងការយល់ខុសពីគ្នាទៅវិញទៅមកនូវរាល់ការលើកលែងការសន្យា និងការធានាលើសេវាជាក់លាក់ណាមួយចំពោះអតិថិជន

៧-ត្រូវពិនិត្យអោយបានល្អិតល្អន់មុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងណាមួយ ដោយបញ្ជាក់ជូនទៅភាគីហត្ថលេខីអំពីកាតព្វកិច្ចដែលភាគីនីមួយៗត្រូវទទួលខុសត្រូវ

៨-ត្រូវរក្សាទុកទ្រព្យនៅកន្លែងមានសុវត្ថិភាព និងមិនត្រូវយកទ្រព្យនោះទៅប្រើប្រាស់ឡើយ

៩-អាជីវករត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាតលើទ្រព្យដែលកើតឡើងក្នុងអំឡុងពេលជាប់កិច្ចសន្យា

១០-ត្រូវផ្តល់ជូនអតិថិជននូវសេវាប្រកបដោយការយកចិត្តទុកដាក់ខ្ពស់

១១-ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ឱ្យនគរបាល ឬសមត្ថកិច្ចពាក់ព័ន្ធ ក្នុងករណីមានការសង្ស័យបទល្មើសនៃអតិថិជន ឬទ្រព្យណាមួយ

១២-ត្រូវផ្តល់ព័ត៌មាន ឬរបាយការណ៍អំពីអត្តសញ្ញាណនៃអតិថិជន និងទ្រព្យ(សៀវភៅចុះបញ្ជីទ្រព្យ) ជូនប៉ុស្តិ៍នគរបាលរដ្ឋបាលសមត្ថកិច្ចដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មយ៉ាងយូររយៈពេល ០៧ថ្ងៃ (ប្រាំពីរថ្ងៃ) បន្ទាប់ពីកាលបរិច្ឆេទទទួលទ្រព្យ

១៣-ត្រូវតាមដាននូវរាល់សភាពការណ៍ដែលអាចជះឥទ្ធិពលដល់លក្ខខណ្ឌទីផ្សារបច្ចុប្បន្ន ដើម្បីផ្តល់ជាដំបូន្មានដល់អតិថិជនរបស់ខ្លួន និង/ឬដើម្បីជួយអតិថិជនក្នុងលក្ខណៈមួយដែលមានការទទួលខុសត្រូវ

១៤-ត្រូវធានាថារាល់ការព្រមព្រៀងដែលពាក់ព័ន្ធទៅនឹងកិច្ចសន្យា ត្រូវតែធ្វើឡើងជាលាយលក្ខអក្សរដោយប្រើប្រាស់ពាក្យពេចន៍ច្បាស់ៗ និងងាយយល់ ព្រមទាំងមានការបញ្ជាក់អោយបានច្បាស់លាស់នូវរាល់លក្ខខណ្ឌកាតព្វកិច្ច និង រាល់អនុសាសន៍ដែលភាគីពាក់ព័ន្ធបានព្រមព្រៀងគ្នា។ រាល់កិច្ចសន្យាដែលបានពិនិត្យនិងចុះហត្ថលេខា ត្រូវតែថតចំលងដើម្បីចែកជូនដល់ភាគីដែលពាក់ព័ន្ធ

១៥-ត្រូវធានាថារាល់ការបង្ហាញនៅក្នុងការផ្សាយពាណិជ្ជកម្មគឺជាការពិត ហើយរាល់ការផ្សព្វផ្សាយអំពីទ្រព្យ

សម្បត្តិ ឬសេវាទាំងអស់ត្រូវតែមានបញ្ជាក់ពីអត្តសញ្ញាណរបស់កន្លែងអាជីវកម្ម និងឈ្មោះបុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ

១៦-ត្រូវរក្សាទុកអោយបានល្អនូវសៀវភៅកត់ត្រា ឯកសារអាជីវកម្ម និងលិខិតស្នាមផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការអាជីវកម្ម

១៧-ត្រូវបិទផ្សាយថ្ងៃ និងពេលវេលាម៉ោងធ្វើការរបស់ខ្លួន នៅនឹងច្រកទ្វារចេញ-ចូលនៃកន្លែងអាជីវកម្មឱ្យបានត្រឹមត្រូវ។ នៅថ្ងៃ ឬម៉ោងដែលប្រកាសបិទមិនធ្វើការនោះ មិនត្រូវទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងប្រមូលការប្រាក់ឡើយ ។ អាជីវករត្រូវជូនដំណឹងទៅក្រសួងអំពីការផ្លាស់ប្តូរពេលវេលាធ្វើការដែលបានបិទនៅលើច្រកទ្វារចេញ-ចូល

១៨-ត្រូវផ្តល់របាយការណ៍ពីប្រតិបត្តិការអាជីវកម្មដោយភ្ជាប់បញ្ជីទ្រព្យមកក្រសួងរៀងរាល់ខែ និងរៀងរាល់ដំណាច់ឆ្នាំ

១៩-មិនត្រូវផ្តល់ប្រាក់កម្ចីដល់អតិថិជន ០១ នាក់ ឬ ០១ ក្រុម លើសពី ២០% នៃដើមទុនអាជីវកម្មនោះឡើយ

២០-មិនត្រូវផ្តល់ប្រាក់កម្ចីលើសពី ២០.០០០.០០០ រៀល សំរាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ ឬឯកសារផ្សេងៗដែលជាកម្មវត្ថុយកមកដាក់បញ្ចាំ

២១-មិនត្រូវធ្វើអាជីវកម្មខុសពីឈ្មោះ ឬអាស័យដ្ឋានរបស់ខ្លួនដែលបានប្រើនៅក្នុងអាជ្ញាប័ណ្ណនោះទេ

២២-មិនត្រូវបង្កវាទប្បដិវាទក្នុងការធ្វើអាជីវកម្មជាមួយអាជីវករដទៃទៀតឡើយ

២៣-មិនត្រូវផ្តល់គំនិត ឬយោបល់ណាមួយដល់អតិថិជនក្រៅអំពីធុរៈកិច្ចនិងបទពិសោធន៍របស់ខ្លួនឡើយ

២៤-មិនអាចធ្វើការផ្លាស់ប្តូរទីកន្លែងធ្វើអាជីវកម្ម ដោយគ្មានការជូនដំណឹងជាមុនយ៉ាងតិច ៣០ថ្ងៃ (សាមសិបថ្ងៃ) ទៅក្រសួងបានឡើយ

២៥-មិនត្រូវទទួលយកទ្រព្យអ្វីមួយពីអនីតិជន ឬពីជនណាដែលកំពុងមានជាតិស្រវឹងជោគជាំក្នុងខ្លួន ឬពីជនណាដែលខ្លួនបានសង្ស័យថាជាចោរ ឬអ្នកទទួលផលចោរកម្ម។

២៦-មិនត្រូវឱ្យអតិថិជនផ្តិតមេដៃលើកិច្ចសន្យា ឬកំណត់ត្រាផ្សេងៗដែលមិនទាន់បានបំពេញត្រឹមត្រូវពេញលេញនោះឡើយ

២៧-មិនត្រូវធ្វើអាជីវកម្មដើម្បីបំរើដល់សកម្មភាពសំអាតប្រាក់ ឬបំរើផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ។ ក្នុងករណីដែលសង្កេតឃើញមានសកម្មភាពនេះ សាមីជនត្រូវរាយការណ៍ជាបន្ទាន់មកក្រសួង ឬអាជ្ញាធរមានសមត្ថកិច្ច

២៨-នៅពេលមានការស្នើសុំអោយផ្តល់យោបល់ ឬវាយតំលៃវត្ថុអ្វីមួយ អាជីវករត្រូវគិត និងធ្វើការវិភាគឱ្យបានល្អិតល្អន់នូវរាល់កត្តាដែលអាចជះឥទ្ធិពលដល់តំលៃវត្ថុត្រូវដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទាន មុននឹងជំរាបជូនដល់អតិថិជនរបស់ខ្លួន។

**ប្រការ១១: ការផ្ទេរអាជ្ញាប័ណ្ណ**

អាជ្ញាប័ណ្ណមិនអាចផ្ទេរទៅអោយអ្នកផ្សេងបានឡើយ លុះត្រាតែមានការអនុញ្ញាតពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ប្រការ១២: ការផ្អាកសកម្មភាពអាជីវកម្ម និងការបញ្ឈប់អាជីវកម្ម

ក្នុងករណីផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់សំណើជាលាយល័ក្ខអក្សរដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ព្រមទាំងបញ្ជាក់អំពីមូលហេតុអោយបានត្រឹមត្រូវមកក្រសួងក្នុងរយៈពេល ៣០ថ្ងៃ (សាមសិបថ្ងៃ) មុនអាជីវកម្មត្រូវបានផ្អាក ឬបញ្ឈប់សកម្មភាពជាស្ថាពរ ។ ការសំរេចលើការផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្មជាសិទ្ធិរបស់ក្រសួង ។

ក្រោយពីបញ្ឈប់អាជីវកម្មហើយ អ្នកកាន់អាជ្ញាប័ណ្ណត្រូវប្រគល់អាជ្ញាប័ណ្ណមកក្រសួងវិញ ។

## ប្រការ១៣: ការព្យួរ ឬដកហូតអាជ្ញាប័ណ្ណ

ក្រសួងមានសិទ្ធិព្យួរ ឬដកហូតអាជ្ញាប័ណ្ណមកវិញ នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តដូចករណីណាមួយដូចខាងក្រោម :

-ពុំបានអនុវត្តអោយបានត្រឹមត្រូវទៅតាមខ្លឹមសារនៃប្រកាសនេះឬលិខិតបទដ្ឋានផ្សេងៗទៀតដែលចេញដោយក្រសួង

-ក្រោយពីទទួលបានការណែនាំពីក្រសួងព្រមទាំងទទួលពិន័យរដ្ឋបាលហើយ អ្នកកាន់អាជ្ញាប័ណ្ណនៅតែបន្តប្រព្រឹត្តល្មើសទៅនឹងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រកាសនេះ

-អ្នកកាន់អាជ្ញាប័ណ្ណខកខានមិនបានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរួមមាន កាតព្វកិច្ចបង់ពន្ធ និងចំណូលផ្សេងៗជូនរដ្ឋ ចាប់ពី ០២ ខែ (ពីរខែ) ជាប់គ្នា

-ករណីកន្លែងអាជីវកម្មក្ស័យធន ឬប្រព្រឹត្តិបទល្មើសក្នុងការធ្វើអាជីវកម្មណាមួយ ក្រសួងនឹងជូនដំណឹងជាលាយលក្ខ័អក្សរ ៣០ថ្ងៃ (សាមសិបថ្ងៃ)មុន ចំពោះកន្លែងអាជីវកម្មដែលនឹងត្រូវដកហូតអាជ្ញាប័ណ្ណ និងចុះផ្សាយអោយសាធារណៈជនបានជ្រាប ឬអាចស្នើទៅតុលាការដើម្បីរឹបអូស ឬឃាត់ទុកវត្ថុដែលដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទាន ។

## ប្រការ១៤: ការចាត់ចែងទៅលើទ្រព្យ

-ក្នុងករណីអតិថិជនពុំមានលទ្ធភាពសងប្រាក់កម្ចី និងការប្រាក់តាមការកំណត់នៅពេលកិច្ចសន្យាដល់កាលវសាន្ត ការចាត់ចែងលើទ្រព្យមានដូចខាងក្រោម:

+សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ទ្រព្យបញ្ចាំនឹងត្រូវចាត់ចែងតាមនីតិវិធីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

+សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ទ្រព្យប្រាតិភោគដោយអនុប្បទាននឹងត្រូវចាត់ចែងតាមលទ្ធភាពជាក់ស្តែង ឬនីតិវិធីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

-ក្នុងករណីអតិថិជនបានសងប្រាក់កម្ចី និងការប្រាក់គ្រប់ចំនួនដូចមានចែងក្នុងកិច្ចសន្យា នោះអាជីវករត្រូវប្រគល់ទ្រព្យទៅឱ្យអតិថិជនវិញភ្លាម ។

អាជីវករមិនមានសិទ្ធិលក់ ផ្ទេរ ឬប្រគល់សិទ្ធិកាន់កាប់ទ្រព្យអោយទៅអ្នកផ្សេងក្នុងកំឡុងពេលដែលទ្រព្យនេះកំពុងជាប់កិច្ចសន្យា លុះត្រាតែមានការឯកភាពពីអតិថិជន ។

**ប្រការ១៥: ការកំណត់អត្រាការប្រាក់ និង រយៈពេលបញ្ញើ**

-អត្រាការប្រាក់ត្រូវបានកំណត់តាមការព្រមព្រៀងរវាងអាជីវករ និងអតិថិជន។ ប៉ុន្តែការព្រមព្រៀងលើអត្រាការប្រាក់នេះមិនត្រូវអោយផ្ទុយពីច្បាប់កំណត់នោះឡើយ ។

-កិច្ចសន្យាមានរយៈពេលយ៉ាងយូរត្រឹម ០៤ ខែ (បួនខែ) ចាប់ពីថ្ងៃបរិច្ឆេទនៃការដាក់ទ្រព្យ និងអាចបន្តសុពលភាពបាន ។

**ប្រការ១៦: កាតព្វកិច្ចពន្ធលើអាជីវកម្ម**

អាជីវករត្រូវបង់ពន្ធទៅអគ្គនាយកដ្ឋានរតនាគារជាតិ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៧: ការបង្កើតសាខា**

អាជីវករអាចបង្កើតសាខាបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួង ហើយត្រូវសុំអាជ្ញាប័ណ្ណសម្រាប់សាខាអាជីវកម្មដោយបំពេញលក្ខខណ្ឌទាំងឡាយដូចមានចែងនៅក្នុងប្រការ ៨ នៃប្រកាសនេះ។

**ប្រការ១៨: របាយការណ៍អាជីវកម្មប្រចាំខែ**

អាជីវករត្រូវផ្តល់ស្ថិតិ និងរបាយការណ៍អាជីវកម្មប្រចាំខែមកក្រសួងមិនអោយលើសពី ១៥ថ្ងៃ នៃខែ បន្ទាប់ ។ ស្ថិតិ និងរបាយការណ៍នោះត្រូវបញ្ជាក់ថាពិត និងត្រឹមត្រូវដោយអ្នកកាន់អាជ្ញាប័ណ្ណ ។

**ប្រការ១៩: របាយការណ៍អាជីវកម្មប្រចាំឆ្នាំ**

ក្នុងរយៈពេល ០៣ ខែ (បីខែ) ក្រោយពីបញ្ចប់ឆ្នាំនីមួយៗ អាជីវករត្រូវផ្តល់ឱ្យក្រសួងនូវរបាយការណ៍អាជីវកម្ម នៃឆ្នាំសារពើពន្ធកន្លងមក ។

**ប្រការ២០: ការត្រួតពិនិត្យបញ្ជី**

ក្រសួងអាចចាត់មន្ត្រីជំនាញ ដើម្បីចុះត្រួតពិនិត្យឯកសារផ្សេងៗដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មតាមការចាំបាច់ ។ អាជីវករត្រូវសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរបស់ក្រសួង ។

**ប្រការ២១: ការដាក់ពិន័យរដ្ឋបាល**

អាជីវករទាំងឡាយណាដែលល្មើសទៅនឹងបទប្បញ្ញត្តិ និងលក្ខខណ្ឌនានាដែលមានចែងក្នុងប្រកាសនេះនឹងត្រូវទទួលទណ្ឌកម្មដូចជា ទទួលការដាក់ពិន័យ ការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណ ដូចមានចែងនៅក្នុងសៀវភៅបន្ទុក។ ក្នុងករណីចាំបាច់ក្រសួងមានសិទ្ធិប្តឹងទៅតុលាការដើម្បីអនុវត្តទណ្ឌកម្មខាងលើ ។

**ប្រការ២២: ការអនុវត្តតាមសៀវភៅបន្ទុក**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តរាល់លក្ខខណ្ឌដែលមានចែងនៅក្នុងសៀវភៅបន្ទុក ស្តីពីលក្ខខណ្ឌអនុវត្តអាជ្ញាប័ណ្ណសំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។

**ប្រការ២៣: អវសានប្បញ្ញត្តិ**

បទប្បញ្ញត្តិ ឬ លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

## ប្រការ២៤: ការអនុវត្តប្រកាស

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កន្លែងអាជីវកម្ម និងបុគ្គលដែលពាក់ព័ន្ធ ត្រូវអនុវត្ត និងប្រតិបត្តិតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

## ប្រការ២៥: សុពលភាពនៃការអនុវត្តប្រកាស

ប្រកាសនេះមានតំលៃអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត

  " ដើម្បីជូនជ្រាប និងសហការអនុវត្ត "
- ដូចមានក្នុងប្រការ ២៤

  " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០៣២ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០

លិខិតចូល
ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ2010

# ប្រកាស
## ស្តីពី ការបង្កើតការិយាល័យ
## គ្រប់គ្រងអាជីវកម្មទទួលបញ្ញើ និងទិញ-លក់ទ្រព្យបញ្ញើ
## និង អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
## នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង អនុក្រឹត្យលេខ ២០អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងការកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

…/…

- បានឃើញអនុក្រឹត្យលេខ ១៣៤.អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០០៩ លើលិខិតលេខ ១១៦៨ សហវ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និង ទិញ-លក់ ទ្រព្យបញ្ចាំ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ លើលិខិតលេខ ០៨២ សហវ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ស្តីពីការគ្រប់គ្រង ការត្រួតពិនិត្យ និងការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- បានឃើញ ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** បង្កើតការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ។

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

**ប្រការ២:** តួនាទី និងភារកិច្ចរបស់ការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានមានដូចតទៅ :

- រៀបចំលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។
- រៀបចំបែបបទផ្តល់ ឬដកហូត ឬព្យួរទុកអាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។
- ត្រួតពិនិត្យតាមដាន និងជំរុញការអនុវត្តនូវរាល់បណ្តាវិធានការ បទបញ្ញត្តិ លិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។
- ជំរុញ និងបង្កើនការកៀរគរចំណូលជូនរដ្ឋពីអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។
- តាមដាន និងជំរុញអោយអ្នកប្រកបអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានទាំងអស់ បង់ចំណូលកាតព្វកិច្ចជូនរដ្ឋអោយទាន់ពេលវេលាទៅតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- ត្រួតពិនិត្យលើបញ្ជីគណនេយ្យ និងឯកសារផ្សេងៗទៀតរបស់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ក្នុងករណីមានភាពមិនប្រក្រតីក្នុងប្រតិបត្តិការអាជីវកម្ម ។
- ចុះត្រួតពិនិត្យដោយផ្ទាល់អំពីសភាពការណ៍អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីធ្វើសេចក្តីរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ។
- បោះពុម្ពផ្សាយព័ត៌មានដែលប្រមូលបាន សំដៅធានាតម្លាភាពទីផ្សារអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន លើកលែងតែព័ត៌មានណាដែលការិយាល័យយល់ឃើញថាជាព័ត៌មានសំងាត់ ឬជាព័ត៌មានដែលធ្វើអោយប៉ះពាល់ដល់ទីផ្សារបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ។
- ធ្វើកិច្ចសហការជាមួយអង្គភាពនៃបណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ក្នុងករណីដែលអ្នកប្រកបអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន អនុវត្តមិនបានត្រឹមត្រូវតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋាន និង ក្រសួងប្រគល់អោយ
- ធ្វើរបាយការណ៍ប្រចាំខែ រួចបញ្ជូនទៅការិយាល័យរដ្ឋបាល ដើម្បីសរុបជូនថ្នាក់ដឹកនាំនាយកដ្ឋាន និងថ្នាក់ដឹកនាំក្រសួង ។

**ប្រការ៣:** ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់នាយកដ្ឋាន ឬអង្គភាពជំនាញដ៏ទៃទៀត ប្រធាននាយកដ្ឋានត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធនោះ ដើម្បីសុំគោលការណ៍ពីថ្នាក់ដឹកនាំក្រសួង រួមគ្នាដោះស្រាយ ។

**ប្រការ៤:** អគ្គលេខាធិការ នាយខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្ត តាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**<u>ចំលងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួង និងស្ថាប័នពាក់ព័ន្ធ

" ដើម្បីជូនជ្រាបជាព័ត៌មាន "

- ដូចប្រការ ០៤ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ...០០១.... សហវ.ប្រក

លិខិតចូល
